# កម្ពុជាក្រោម

ព្រឹត្តិបត្រពោះពុម្ពផ្សាយជារៀងរាល់ខែដោយសហព័ន្ធខ្មែរកម្ពុជាក្រោម

លេខ ១៨ ឆ្នាំទី ០២ – ខែមិថុនា គ.ស. ២០០៥ – ព.ស. ២៥៤៩ – N$^0$ 18, June 2005

## សុន្ទរកថារបស់សហព័ន្ធខ្មែរកម្ពុជាក្រោម នាទិវា ៤ មិថុនា

**សុន្ទរកថារបស់សហព័ន្ធខ្មែរកម្ពុជាក្រោម ផ្ញើជូនជនរួមជាតិខ្មែរកម្ពុជាក្រោម នាឱកាសកាន់ទុក្ខគម្រប់ខួប ៥៦ ឆ្នាំ នៃថ្ងៃអាណានិគមនិយមបារាំង កាត់ទឹកដីកម្ពុជាក្រោមឲ្យទៅអាណានិគមយួន (៤ មិថុនា ១៩៤៩ – ៤ មិថុនា ២០០៥) ថ្លែងដោយ លោក ថាច់ សិរ ប្រធានសតាតំណាងសហព័ន្ធខ្មែរកម្ពុជាក្រោម ដែលមានខ្លឹមសារទាំងស្រុងដូចតទៅ ៖**



*–សូមនមស្សការចំពោះប្រជុំបី នៃព្រះត្រៃរតន៍ដោយសេចក្តីគោរព ។*

*–សូមគោរពព្រះវិញ្ញាណក្ខន្ធ និងវិញ្ញាណក្ខន្ធ វីរសមណ: វីរបុរសជាតិ ដ៏ឧត្តុង្គឧត្តម ។*

*–សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរ:គ្រប់ព្រះអង្គ ជាទីសក្ការ: ។*

*–សូមសួរសុខទុក្ខ និងគោរពបងប្អូនរួមឈាមជាតិខ្មែរ ជាទីស្រឡាញ់រាប់អាន ។*

ថ្ងៃនេះជាទិវាប្រវត្តិសាស្ត្រ ដ៏សែនឈឺចាប់ខ្លោចផ្សាបំផុត ដែលជនរួមឈាមខ្មែរក្រោម មិនអាចបំភ្លេចបាននូវអំពើព្រៃផ្សៃរបស់អាណានិគមយួន ។ ថ្ងៃ ០៤ មិថុនា ២០០៥ ជាថ្ងៃគម្រប់ខួប ៥៦ ឆ្នាំ នៃថ្ងៃអាណានិគមយួនត្រួតត្រាលើជនជាតិដើមខ្មែរក្រោម ។ បងប្អូនរួមឈាម នៅគ្រប់ទីកន្លែង និង សមាគមខ្មែរក្រោមនានា បានប្រារព្ធពិធី បុណ្យដារ បង្សុកូល ឧទ្ទិសមហាកុសលប្រគេន ថ្វាយជូនព្រះវិញ្ញាណក្ខន្ធ និង វិញ្ញាណក្ខន្ធ ព្រះវីរសមណ: វីរបុរសខ្មែរ ដែលបានបូជាព្រះកាយ ថ្វាយជីវិត ក្នុងបុព្វហេតុជាតិ សាសនា និងទឹកដីកម្ពុជាក្រោម ។ ការជួបជុំគ្នាជារៀងរាល់ឆ្នាំ និងពិធីកាន់ទុក្ខនាថ្ងៃនេះ (៤ មិថុនា ១៩៤៩ – ៤ មិថុនា ២០០៥) របស់បងប្អូនរួមឈាមខ្មែរក្រោមនៅតាមតំបន់នានា គឺជាការសម្តែងនូវកតញ្ញូកតវេទិតាធម៌ចំពោះវិញ្ញាណក្ខន្ធបុព្វបុរសគ្រប់ជំនាន់ដែលបានធ្វើពលិកម្ម ក្នុងបុព្វហេតុពូជសាសន៍ ប្រពៃណី វប្បធម៌ អក្សរសាស្ត្រ ទំនៀមទម្លាប់ និងព្រះពុទ្ធសាសនានៅកម្ពុជាក្រោម ។

តាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ន ភាពគង់វង្សនៃពូជសាសន៍ វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី និងព្រះពុទ្ធសាសនានៅកម្ពុជាក្រោម ជាងនេះទៅទៀត ខ្មែរក្រោមត្រូវបានសហគមន៍អន្តរជាតិ ទទួលស្គាល់ពេញសិទ្ធិថា ខ្មែរក្រោមជាជនជាតិដើមនោះ ក៏ដោយសារបងប្អូនខ្មែរក្រោម នៅគ្រប់តំបន់មិនភ្លេចនូវអត្តសញ្ញាណជាតិខ្មែរក្រោម ហើយតែងតែរក្សានូវឧត្តមគតិស្នេហាជាតិ គ្រប់កាលៈទេសៈប្រកបដោយមនសិការជាតិដ៏ខ្ពង់ខ្ពស់ ។ ទឹកដីកម្ពុជាក្រោមសព្វថ្ងៃ បានស្ថិតក្រោមការត្រួតត្រារបស់អាណានិគមយួន ចាប់ពីថ្ងៃទី

### មាតិការឿង

–សុន្ទរកថារបស់សហព័ន្ធខ្មែរ..........១
–ច្បាប់សិទ្ធិមនុស្ស និងខ្មែរក្រោម..........៣
–សេចក្តីថ្លែងការណ៍របស់ខ្មែរកម្ពុជាក្រោម..........៤
–សេចក្តីប្រកាសព័ត៌មានស្តីអំពីបាតុកម្ម..........៦
–សង្គ្រាមខ្មែរយួនក្នុងអង្គការ..........៧
–ពិធីអបអរសាទរសហព័ន្ធខ្មែរ..........៨
–អជ្ញាធរយួនខេត្តឃ្លាំងរំលោភបំពាន..........១០
–អជ្ញាធរយួនឃុំចូវឡាំងរុះរើសាលា..........១១
–អជ្ញាធរយួនដកសិទ្ធិព្រះចៅអធិការវត្ត..........១១
–រឿងកំពប់តែអុង..........១២
–កំណាព្យ សម្រែកខ្មែរក្រោម..........១៤

ទីស្នាក់ការ ៖ P.O. Box 0193, Pennsauken, NJ 08110-0193, USA, Tel: (856) 583-1503, email: kkfnewsletter@khmerkrom.net, http://www.khmerkrom.net

៤ ខែមិថុនា ឆ្នាំ ១៩៤៩ រហូតមក ទោះជាយ៉ាងនេះក្តី ក៏បងប្អូនរួមឈាមខ្មែរក្រោម នៅតែចាត់ទុកដែនដីកម្ពុជាក្រោមជាកម្មសិទ្ធិស្របច្បាប់របស់ខ្លួនជានិច្ច ហើយចាត់ទុកទង្វើរបស់អាណានិគមបារាំង ជាទង្វើខុសច្បាប់ទាំងស្រុង ។ ការកាត់ទឹកដីកម្ពុជាក្រោម ឲ្យទៅរដ្ឋការយួន គឺជាការឃុបឃិតដ៏អាក្រក់បំផុតរវាងអាណានិគមបារាំង និងរដ្ឋការយួនបាវដាយ ដែលប្រជាពលរដ្ឋខ្មែរក្រោមរាប់លាននាក់ ជាម្ចាស់ទឹកដីមិនបានដឹងសោះ ។

ឆ្លៀតឱកាសនៃការសម្តែងទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំព្រះករុណាខ្ញុំ តាងនាមអធិបតីសហព័ន្ធខ្មែរកម្ពុជាក្រោម សូមសម្តែងនូវការគោរព និងដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ចំពោះគុណូបការៈដ៏ថ្លៃថ្លារបស់គណៈកម្មការសកម្ម សមាជិកសមាជិកា សាខាសហព័ន្ធ សមាគមខ្មែរក្រោមនានា និងបងប្អូនរួមជាតិទាំងអស់ ដែលកំពុងរស់នៅជុំវិញពិភពលោក មាននៅព្រះរាជាណាចក្រកម្ពុជា ញូវស្សេឡែន កាណាដា បារាំង អូស្ត្រាលី និងសហរដ្ឋអាមេរិកជាដើម ជាពិសេសព្រះសង្ឃ និងបងប្អូនរួមឈាមខ្មែរក្រោម ដែលកំពុងរស់នៅឯមាតុភូមិដ៏សែនកំសត់នៃយើង តែងតែចូលរួមយ៉ាងសកម្មចំពោះកិច្ចការសង្គមជាតិ និងសាសនា ហើយគាំទ្រចលនាតស៊ូដោយអហិង្សារបស់អង្គការសហព័ន្ធខ្មែរកម្ពុជាក្រោម ទាំងស្មារតី ទាំងកម្លាំងកាយចិត្ត និងកម្លាំងថវិកាយ៉ាងពេញទំហឹង ។

*–ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ* !

*–បងប្អូនរួមជាតិខ្មែរ ជាទីគោរពស្រឡាញ់រាប់អានយ៉ាងស្មោះស្ម័គ្រជាទីបំផុត* !

យើងទាំងអស់គ្នា ពិតជាមានការសោកស្តាយនឹកស្រណោះអាលោះអាល័យពន់ពេកក្រៃ ដោយមាតុភូមិរបស់យើងកំពុងស្ថិតនៅក្រោមរបបអាណានិគមយួន សព្វថ្ងៃ ទោះបីសភាពការណ៍ខ្មែរក្រោមកំពុងមានភាពតានតឹង និងមិនទាន់ទទួលបានសិទ្ធិសេរីភាពគ្រប់គ្រាន់នៅឡើយក្តី ក៏ខ្មែរក្រោមនៅតែខំប្រឹងប្រែងត្រដរតស៊ូ រក្សានូវទំនៀមទម្លាប់ ប្រពៃណី វប្បធម៌ ជំនឿសាសនា និងអត្តសញ្ញាណជាតិ គ្រប់របបនយោបាយរបស់យួន ។

ចរន្តសិទ្ធិមនុស្សរបស់ជាតិសាសន៍លើពិភពលោក ត្រូវបានគាំពារដោយអង្គការសហប្រជាជាតិ ។ ស្របតាមច្បាប់លទ្ធិប្រជាធិប–តេយ្យ អង្គការសហព័ន្ធខ្មែរកម្ពុជាក្រោម ក៏បានរួបរួមគំនិតធ្វើសកម្ម–ភាព ចលនាតស៊ូដោយអហិង្សាជុំវិញពិភពលោក ទទួលបាននូវលទ្ធ–ផលជាវិជ្ជមានជាបន្តបន្ទាប់លើឆាកអន្តរជាតិ ។

ទិសដៅ និងគោលបំណងធំរបស់អង្គការសហព័ន្ធខ្មែរ–កម្ពុជាក្រោម នាបច្ចុប្បន្ន និងអនាគត គឺមាន ៣ ចំណុច ៖ ទី ១ ***កម្លាំងធនធានមនុស្ស*** ទី ២ ***កម្លាំងសេដ្ឋកិច្ច*** និងទី ៣ ***កម្លាំងគាំទ្រពីអន្តរជាតិ*** ។ កម្លាំងទាំង ៣ ខាងលើនេះ គឺជាស្នូលនៃផែនការ បានអនុវត្តកន្លងមក និងកំពុងអនុវត្តសព្វថ្ងៃ ហើយទទួលបានជោគជ័យជាបន្តបន្ទាប់នៃប្រវត្តិសាស្ត្រខ្មែរក្រោម ។

ជាទីអវសាន ខ្ញុំព្រះករុណាខ្ញុំ តាងនាមអធិបតីសហព័ន្ធខ្មែរកម្ពុជាក្រោម សង្ឃឹមយ៉ាងមុតមាំ ចំពោះកម្លាំងស្មារតីតស៊ូស្នេហាជាតិ និងសូមអំពាវនាវដល់បងប្អូនរួមឈាមខ្មែរនៅគ្រប់តំបន់ ចូលរួមគាំទ្រសកម្មភាពចលនាអហិង្សារបស់អង្គការសហព័ន្ធខ្មែរកម្ពុជាក្រោមដើម្បីជំរុញនាវាកម្ពុជាក្រោម ឲ្យមានល្បឿនទៅមុខ ប្រកបដោយមនសិការជាតិ ដើម្បីទាមទារសិទ្ធិសេរីភាព សម្រេចវាសនាខ្លួនដោយខ្លួនឯង ក្នុងនាមខ្មែរក្រោមជាម្ចាស់ស្រុក ។

សូមក្រាបថ្វាយបង្គំ ប្រគេនពរ និងជូនពរ ចំពោះបងប្អូនរួមឈាមខ្មែរនៅគ្រប់ទីកន្លែង ទទួលបានជោគជ័យ គ្រប់បេសកកម្មការ–ងារសង្គមជាតិ និងសាសនា ក្នុងពេលដ៏ខ្លីខាងមុខនេះ ៕

*សូមអរព្រះគុណ និងសូមអរគុណ* !





ទិដ្ឋភាពខាងមុខសារមន្ទីរជាតិខ្មែរកម្ពុជាក្រោម និងការពិព័រណ៍នូវការសម្តែងរឿងអំពីប្រវត្តិសាស្ត្រខ្មែរនៅក្នុងទីក្រុង ខាន់តូ


និពន្ធនាយក ៖ **ថាច់ ប៊ុកថាច់** ផ្សព្វផ្សាយ ៖ **សឺន រតនៈ, សឺន ច័ន្ទ**

ឯកសារ PDF មាននៅក្នុងគេហទំព័រ www.khmerkrom.net

# ច្បាប់សិទ្ធិមនុស្ស និងខ្មែរក្រោម

នៅពេលដែលអង្គការសហប្រជាជាតិបង្កើតឡើង នៅឆ្នាំ ១៩៤៥ ស្ថាបនិករដ្ឋទាំងអស់បានអះអាងលើសិទ្ធិមនុស្ស សេចក្តីថ្លៃថ្នូរ តម្លៃមនុស្ស និងសិទ្ធិស្មើភាពគ្នារវាងបុរស និងស្ត្រី ។ គេបានបង្ហាញនូវឆន្ទៈដ៏មោះមុតដើម្បីបង្កើតឲ្យមានសិទ្ធិមនុស្ស និងសេរីភាព លើពិភពលោកដែលត្រូវតែគោរព និងប្រតិបត្តិតាមសម្រាប់មនុស្សទាំងអស់ ដោយមិនមានការប្រកាន់ពីពូជសាសន៍ ភាសា ឬ សាសនាឡើយ ។

ច្បាប់សិទ្ធិមនុស្សសកល បានប្រកាសឡើងនៅឆ្នាំ ១៩៤៨ ដែលយោងលើសេចក្តីសម្រេចខាងលើនេះ ។ ច្បាប់សិទ្ធិមនុស្សសកលនេះ បានក្លាយជាមូលដ្ឋានធម្មនុញ្ញ និងច្បាប់ជាតិនាប្រទេសធំ ៗ មួយចំនួន ។ សិទ្ធិនេះបានដាក់តម្កល់ក្នុងការប្រកាសជាសកល ហើយបានរៀបចំយ៉ាងល្អិតល្អន់ ដើម្បីឲ្យក្លាយជាមូលដ្ឋានច្បាប់អន្តរជាតិ ដែលយល់ព្រមក្នុងឆ្នាំ ១៩៦៦ នៃច្បាប់សិទ្ធិស៊ីវិល សិទ្ធិនយោបាយ ហើយនិងច្បាប់សេដ្ឋកិច្ច សង្គមកិច្ច និងសិទ្ធិវប្បធម៌ និងសិទ្ធិសញ្ញាជាច្រើនទៀត រួមទាំងការបំបាត់នូវការប្រកាន់ពូជសាសន៍ ស្ត្រី កុមារ និងច្បាប់ប្រឆាំងនឹងការធ្វើទារុណកម្ម ។ល។ និង ។ល។

តើ "**សិទ្ធិមនុស្ស**" មានន័យដូចម្តេចទៅ ?

មនុស្សកើតមក មានសេចក្តីថ្លៃថ្នូរ និងសិទ្ធិស្មើ ៗ គ្នា ។ ទាំងអស់នេះឯងជាសីលធម៌ ដែលមនុស្សលោកគ្រប់រូបត្រូវមាន ។ ការរួមផ្តុំទាំងអស់ហ្នឹងហើយ ដែលបច្ចុប្បន្ននេះ ហៅថាសិទ្ធិមនុស្ស ជាសិទ្ធិដែលមាននៅក្នុងច្បាប់ ដើម្បីប្រើប្រាស់ក្នុងសង្គម គឺទាំងក្នុងប្រទេស និងសកលលោក ។

តើខ្មែរក្រោម អាចយកច្បាប់សិទ្ធិមនុស្សមកការពារអំពើជិះជាន់ពីក្រុងហាណូយបានឬទេ ?

ជាការពិតណាស់ សិទ្ធិមនុស្សត្រូវបានគោរព និងទទួលស្គាល់ជាសកល ដូច្នេះខ្មែរក្រោមមានសិទ្ធិគ្រប់គ្រាន់ ដើម្បីយកច្បាប់នេះ មកការពារខ្លួនពីអំពើរំលោភទាំងឡាយរបស់រដ្ឋាភិបាលអាណានិគមក្រុងហាណូយ ។ រដ្ឋាភិបាលអាណានិគមយួន ជាសមាជិករបស់អង្គការសហប្រជាជាតិ ដោយបានចុះកិច្ចយល់ព្រមលើសិទ្ធិ ៥ ក្នុងចំណោម ៦ របស់អង្គការសហប្រជាជាតិ ។ តើក្រុងហាណូយបានអនុវត្តប៉ុន្មានហើយ ទៅលើអ្វីដែលខ្លួនបានចុះកិច្ចយល់ព្រមនោះ ? ការពិតគឺគ្មានមួយណាច្បាស់លាស់ ដែលគេបានគោរពនោះទេ ។ អ្វី ៗ ដែលគេធ្វើ ឬមានរបាយការណ៍ មកបង្ហាញអង្គការសហប្រជាជាតិ និងប្រទេសនានានោះ គឺក្នុងគោលបំណងបម្រើផែនការគេប៉ុណ្ណោះ ដូចជាទទួលជំនួយដើម្បីពង្រឹងសេដ្ឋកិច្ចគេ ដើម្បីចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកតែប៉ុណ្ណោះ ។ល។ និង ។ល។

តើខ្មែរក្រោម ត្រូវធ្វើយ៉ាងណាដើម្បីឲ្យក្រុងហាណូយគោរពនូវអ្វី ដែលគេបានចុះហត្ថលេខានៅអង្គការសហប្រជាជាតិនោះ ? ខ្មែរក្រោមទាំងនៅក្នុងស្រុក ក៏ដូចជានៅក្រៅស្រុក រួមទាំងនៅព្រះរាជាណាចក្រកម្ពុជាផង ត្រូវតែរួបរួមគ្នា ដើម្បីពាំនាំយកនូវទុក្ខវេទនាទាំងឡាយ អំពើជិះជាន់ទាំងឡាយ អំពើរឹបអូសយកដីស្រែ ទ្រព្យសម្បត្តិ ការគំរាមកំហែង ចាប់ដាក់គុក ចោទប្រកាន់ ។ល។ និង ។ល។ ដល់អង្គការសហប្រជាជាតិដោយផ្ទាល់ ឬ តាមរយៈសហព័ន្ធខ្មែរកម្ពុជាក្រោម ដែលនឹងពាំនាំយកនូវសោកនាដកម្មនៃអំពើជិះជាន់ទាំងនោះ ជូនអង្គការសហប្រជាជាតិ ដូចដែលបានធ្វើនៅខែមេសា ឆ្នាំ ២០០៥ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស នាសន្និបាតលើកទី ៦១ និងនៅខែឧសភា ឆ្នាំ ២០០៥ កន្លងទៅថ្មី ៗ នៅអង្គការសហប្រជាជាតិ បូរីញូវយ៉កនៃសហរដ្ឋអាមេរិក ៕

"*សាមគ្គីភាព កើតឡើងដោយសេចក្តីស្មោះត្រង់ចំពោះជាតិ មិនមានគិតពីប្រយោជន៍ផ្ទាល់ខ្លួន មិនមានកើតនូវសេចក្តីមានះ ដែលជាកត្តាបរាជ័យ និងបម្រើផលប្រយោជន៍សត្រូវ*" ។

**ចាច់ ង៉ុក ចាច់**

**សេចក្តីថ្លែងការណ៍របស់ខ្មែរកម្ពុជាក្រោម ក្នុងវេទិកាអចិន្ត្រៃយ៍នៃអង្គការសហប្រជាជាតិស្តីអំពីជាតិដើម  ឆ្នាំទី ៤ ប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១៧-២៦ ឧសភា នាបូរីញូវយ៉ក  រួមមាន ៨ ប្រធានបទដែលមានខ្លឹមសារ ដូចតទៅៈ**

## ប្រធានបទបទី ១   ស្តីពីភាពក្រីក្រ និងគ្រោះទុរ្ភិក្ស

## ថ្លែងដោយលោក  យឿង វ៉ាង



*លោកស្រីប្រធាន និង សមាជិកសមាជិកាទាំងឡាយនៃវេទិកាអចិន្ត្រៃយ៍ស្តីពីបញ្ហាជនជាតិដើម រួមទាំងអស់លោក លោកស្រី ជាភ្ញៀវកិត្តិយសទាំងអស់ ជាទីគោរព* !

ក្នុងនាមសហព័ន្ធខ្មែរកម្ពុជាក្រោម ខ្ញុំសូមថ្លែងសុន្ទរកថាដែលស្តីអំពីភាពក្រីក្រ និងគ្រោះទុរ្ភិក្សជូនអង្គវេទិកាជ្រាប ។ យើងខ្ញុំជាខ្មែរកម្ពុជាក្រោម គឺជាជនជាតិដើមនៅដែនដីសណ្តទន្លេមេគង្គ ភាគខាងត្បូងនៃប្រទេសវៀតណាម ។ បច្ចុប្បន្ននេះ អង្គការពិភពលោកមិនបានដឹងឮ ពីភាពខ្វះខាតរបស់ខ្មែរក្រោមទេ ពីព្រោះតែមានការបិទបាំងដោយរបបគ្រប់គ្រងកុម្មុយនិស្តវៀតណាម ។ រដ្ឋាភិបាលវៀតណាម បានបន្តនយោបាយដ៏ឃោរឃៅរបស់ពួកគេទៅលើប្រជា-ពលរដ្ឋខ្មែរក្រោម ដែលប្រឈមមុខនឹងភាពក្រីក្រ និងគ្រោះទុរ្ភិក្សយ៉ាងធ្ងន់ធ្ងរ ។

បច្ចុប្បន្ននេះ ប្រជាពលរដ្ឋខ្មែរក្រោមកំពុងទទួលរងនូវទុក្ខ-វេទនាយ៉ាងដំណំដែលកើតមានឡើងច្រំដែល ៗ ដែលធ្វើឲ្យប្រែប្រួលដល់ជីវភាពរបស់ពួកគេ ក្នុងការលុបបំបាត់ភាពក្រីក្រ និងគ្រោះទុរ្ភិក្សដែលខ្មែរក្រោមជួបប្រទះមានដូចជា ៖

១-ប្រជាពលរដ្ឋខ្មែរក្រោម ត្រូវបានរដ្ឋអំណាចវៀតណាមដកហូតឋានៈជាប្រជាពលរដ្ឋស្របច្បាប់ក្នុងសង្គមវៀតណាម ។

២-រដ្ឋាភិបាលវៀតណាម បានគ្រប់គ្រងភូមិស្រុកខ្មែរក្រោម និងរឹបអូសដីធ្លីខ្មែរក្រោមដោយប្រើកម្លាំងទ័ព ធ្វើឲ្យប្រជាពលរដ្ឋខ្មែរ-ក្រោមជាច្រើនពាន់គ្រួសារគ្មានផ្ទះសម្បែង និង ស្ថិតក្នុងភាពស្រេក-ឃ្លាន ។

៣-សិទ្ធជាពលរដ្ឋ ត្រូវបានបដិសេធចំពោះប្រជាពលរដ្ឋខ្មែរក្រោម និង ការរឹបអូសយកដីធ្លីពីសំណាក់រដ្ឋអំណាចវៀតណាម រួមទាំងភូមិស្រុកខ្មែរក្រោមមិនត្រូវបានការពារ ។

៤-សិទ្ធិដ៏មានតម្លៃរបស់ប្រជាពលរដ្ឋខ្មែរក្រោម និងជីវិតរស់នៅដ៏សមរម្យមិនដឹងស្វែងរកនៅកន្លែងណាទេ ។ ប្រជាពលរដ្ឋខ្មែរ-ក្រោម នៅតែរស់នៅក្នុងជីវភាពក្រលំបាក និងទុរ្ភិក្ស ជាបន្ត ។

៥-កង្វះវិស័យសិក្សាអប់រំ ផ្នែកសេដ្ឋកិច្ចចំពោះប្រជាពលរដ្ឋខ្មែរក្រោម ។

៦-ខ្វះការបណ្តុះបណ្តាលផ្នែកកសិកម្មឲ្យបានត្រឹមត្រូវ និង គ្មានបច្ចេកវិទ្យាទំនើប ដែលជាហេតុធ្វើឲ្យកសិផលមិនមានការកើនឡើង ។

៧-សហាគមន៍កសិករខ្មែរក្រោម ពីជំនាន់មួយទៅជំនាន់មួយមានការអន់ថយដូចជាទាសករ ។

៨-មានវិបត្តិខាងសុខុមាលភាព នៅក្នុងសហាគមន៍ខ្មែរក្រោម ដែលបណ្តាលមកពីភាពក្រីក្រ ។

៩-ជំងឺខ្វាក់ភ្នែកដ៏គ្រោះថ្នាក់ បានកើតមកលើប្រជាពលរដ្ឋខ្មែរក្រោមក្រីក្រជាង ៣០០០ គ្រួសារ នៅទូទាំងខេត្តឃ្លាំង និង ខេត្តព្រះត្រពាំង ដោយសារតែកាកសំណល់គីមីពុលរបស់រដ្ឋាភិបាលវៀតណាម ។

*អស់លោក លោកស្រី ជាទីគោរព* !

មុនពេល ដែលខ្ញុំនឹងបញ្ចប់នូវសុន្ទរកថារបស់ខ្ញុំនាពេលនេះ ខ្ញុំសូមលើកយកនូវចំណាប់អារម្មណ៍របស់លោក Nelson Mandela អតីតប្រធានាធិបតីអាហ្វ្រិកខាងត្បូង នៅឯជំនួបកំពូលនៅទីក្រុងឡុងប្រទេសអង់គ្លេស ដែលថា ៖ "ភាពក្រីក្រមិនមែនជាលក្ខណៈធម្មជាតិទេ វាកើតឡើងដោយសារមនុស្ស ហើយវាអាចមានជ័យជម្នះ និងបរាជ័យក៏ដោយសារសកម្មភាពនៃមនុស្សទាំងឡាយ ។ ការជំរះភាព

គ្រីក្រ មិនមែនជាកាយវិការមនុស្សធម៌ទេ វាគឺជាការការពារសិទ្ធិជាមូលដ្ឋាននៃមនុស្ស សិទ្ធិដែលមានតម្លៃ និងជីវិតមួយត្រឹមត្រូវ” ។

ក្នុងហេតុផលនេះ យើងខ្ញុំ ជាប្រជាពលរដ្ឋខ្មែរក្រោម មិនស្វែងរកអ្វីច្រើនជាងសិទ្ធិរបស់យើងខ្ញុំនៅក្នុងសង្គម និង សេដ្ឋកិច្ចដ៏សមរម្យនៅក្នុងភូមិស្រុកកម្ពុជាក្រោម (វៀតណាមខាងត្បូង) ដែលត្រូវបានដកហូត និងមិនបានទទួលការយកចិត្តទុកដាក់ពីរដ្ឋអំណាចវៀតណាមជាយូរលង់ណាស់មកហើយ នៅក្នុងសង្គមខ្មែរក្រោមរបស់យើងខ្ញុំ ។

លោកស្រីប្រធាន អស់លោក លោកស្រី និងភ្ញៀវកិត្តិយស ទាំងអស់ជាទីគោរព ដែលអនុញ្ញាតឲ្យខ្ញុំបានថ្លែងសុន្ទរកថារបស់ខ្ញុំក្នុងនាមតំណាងឲ្យប្រជាពលរដ្ឋខ្មែរក្រោម ។ ខ្ញុំសូមកោតសរសើរយ៉ាងស្មោះស្ម័គ្រនូវគំនិតផ្ដើមវេទិកានេះឡើង និងគោលបំណងរបស់អស់លោកអ្នកទៅលើ “ការលុបបំបាត់ភាពក្រីក្រ និងទុរ្ភិក្ស” ហើយនិងបញ្ហាផ្សេង ៗ ទៀត ។

ជាថ្មីម្ដងទៀត សូមអរគុណចំពោះបុព្វហេតុដ៏ថ្លៃថ្នូសម្រាប់មនុស្សធម៌របស់អស់លោកអ្នកទាំងឡាយ ៕

*សូមអរគុណ លោកស្រីប្រធាន* !

# ប្រធានបទទី ២ ស្ដីពីវិស័យសិក្សាអប់រំផ្នែកព្រះពុទ្ធសាសនា

## ថ្លែងដោយព្រះមហាថេរ **កាន សុផល**



*លោកស្រីប្រធានជាទីគោរព* !

ខ្ញុំព្រះករុណាអាត្មាភាពនាម កែន សុផល ជាព្រះសង្ឃខ្មែរ-កម្ពុជាក្រោមមួយរូបតែងតែស្រឡាញ់នូវសន្តិភាព ។ អាត្មាភាពយើងខ្ញុំខិតខំយ៉ាងខ្លាំងដើម្បីការពារ និងផ្គត់ផ្គង់ជីវិតទាំងឡាយ ថែរក្សា និងគោរពសេរីភាពអ្នកដទៃ រួមទាំងសិទ្ធិមនុស្សជាដើម ។

អស់រយៈពេល ៥៦ ឆ្នាំដែលរស់នៅក្រោមរបបអាណានិគមវៀតណាម ព្រះសង្ឃខ្មែរក្រោម បានទទួលរងនូវទុក្ខវេទនាយ៉ាងច្រើនសន្ធឹកសន្ធាប់គ្មានទីបញ្ចប់ដោយអយុត្តិធម៌ និងការរំលោភសិទ្ធិមនុស្សពីសំណាក់រដ្ឋអំណាចវៀតណាម ។ មិនមែនជារយករណីទេ ប៉ុន្តែជាពាន់ករណី ដែលព្រះសង្ឃខ្មែរក្រោមនៃអាត្មាភាពយើងខ្ញុំ បានទទួលរងនូវការឈឺចាប់ជាយូរមកហើយ ដូចជាការចោទប្រកាន់ដោយគ្មានហេតុផល ការចាប់ខ្លួន ការដាក់ពន្ធនាគា និងការធ្វើទារុណកម្មរហូតដល់បាត់បង់ជីវិតជាដើម ។ រហូតមកទល់បច្ចុប្បន្ននេះ ប្រភេទនៃការអនុវត្តអំពើអមនុស្សធម៌ទាំងនោះ នៅតែអនុវត្តជាបន្តដោយគ្មានការផ្លាស់ប្ដូរសញ្ញាអ្វីបន្តិចណាសោះឡើយ ។

ជាសក្ខីភាពនៃសហគមន៍ជាមិត្តទូទាំងពិភពលោករបស់អាត្មាភាពយើងខ្ញុំក្នុងថ្ងៃនេះ ដែលតែងតែស្រឡាញ់នូវសន្តិភាព និងសេរីភាព ខ្ញុំព្រះករុណាអាត្មាភាព ក្នុងនាមនៃព្រះសង្ឃខ្មែរក្រោម ២៥០០០ អង្គ ដែលរស់នៅក្រៅប្រទេស និងនៅកម្ពុជាក្រោម សូមប្រកាសមិនយល់ព្រមដូចតទៅ ៖

១-រដ្ឋាភិបាលវៀតណាម ត្រូវតែបញ្ចប់នូវគោលនយោបាយបោកបញ្ឆោតរបស់ខ្លួនមកលើប្រជាជាតិខ្មែរក្រោម ។ រដ្ឋាភិបាលវៀតណាម ត្រូវតែបញ្ចប់នូវការឆបោកដ៏ព្រៃផ្សៃមកលើសហគមន៍ខ្មែរ-ក្រោម ។ រដ្ឋាភិបាលវៀតណាម ត្រូវតែបញ្ចប់នូវផែនការលាបពណ៌ដើម្បីបំផ្លាញឫសគល់ អត្តសញ្ញាណ វប្បធម៌ សាសនា និងប្រពៃណីខ្មែរក្រោម ។ នៅទូទាំងខេត្តមាត់ជ្រូកទាំងមូល ក្នុងឆ្នាំ ១៩៧៨ រដ្ឋាភិបាលវៀតណាម បង្ខំឲ្យប្រជាជាតិខ្មែរក្រោមចាកចេញពីស្រុកកំណើត និងបង្ខំព្រះសង្ឃខ្មែរក្រោមឲ្យចាកចេញពីទីវត្តអារាម ដើម្បីឲ្យរដ្ឋាភិបាលវៀតណាម យកទីកន្លែងទាំងនោះធ្វើជាជំរុំទាហានរបស់ពួកវា ។ កាលពីមុន វត្តខ្មែរក្រោមទាំងអស់មានចំនួន ៧០០ វត្ត ជាអកុសលមានវត្តចំនួន ១៤០ ត្រូវបានបំផ្លាញក្នុងសម័យសង្គ្រាម ។ បច្ចុប្បន្ននេះ នៅសល់វត្តតែចំនួន ៥៦០ ប៉ុណ្ណោះ និងកំពុងស្ថិតក្រោមការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរគ្រប់ពេលវេលា ។ ទីវត្តអារាមទាំងនោះធ្លាប់ជាទីកន្លែងមានភាពស្ងប់ស្ងាត់ និងជាកន្លែងដើម្បីឲ្យកូនចៅខ្មែរ-ក្រោមរៀនសូត្រ ដើម្បីផ្ដល់ក្ដីស្រឡាញ់ ដើម្បីស្នាក់នៅរៀនសូត្រ ហើយដើម្បីបង្កើននូវចំណេះដឹងនិងប្រាជ្ញារបស់ពួកគេ ប៉ុន្តែឥឡូវបានប្រែក្លាយទៅជាកន្លែងមួយដើម្បីដាក់ទណ្ឌកម្មដល់ព្រះសង្ឃ និងប្រជាជាតិខ្មែរក្រោមនៃអាត្មាភាពយើងខ្ញុំទៅវិញ ។ ទីវត្តអារាមនៅកម្ពុជាក្រោម លែងជាកន្លែងមានសុវត្ថិភាព និងមាំមួនទៀតហើយ ។ វត្តអារាមមួយចំនួន មានភ្នាក់ងារសម្ងាត់វៀតណាមពួនលាក់ខ្លួនដើម្បីឃ្លាំមើលយ៉ាងម៉ត់ចត់ទៅលើសកម្មភាពព្រះសង្ឃខ្មែរក្រោម និងពួកវាបានរារាំងដល់ឆន្ទៈព្រះសង្ឃខ្មែរក្រោមនៅគ្រប់ទីវត្តអារាម ដោយដាក់ឲ្យព្រះសង្ឃខ្មែរក្រោមអនុវត្តនូវច្បាប់ថ្មី ឬក៏ច្បាប់ដែលមិនសមរម្យទៅនឹងការប្រតិបត្តិផ្នែកព្រះពុទ្ធសាសនាសោះឡើយ ដូចជាបង្ខំឲ្យព្រះ-

សង្ឃខ្មែរក្រោមធ្វើស្រែចំការ ជីកស្រះដើម្បីចិញ្ចឹមត្រី និងចិញ្ចឹមសត្វពាហនៈជាដើម ។

២–រដ្ឋាភិបាលវៀតណាម ត្រូវតែបញ្ចប់នូវការគំរាមកំហែងទៅលើប្រជាជាតិខ្មែរក្រោមដែលជាក្រុមជនជាតិភាគតិច និងធ្វើការប្រឆាំងយ៉ាងសម្ងាត់ទៅនឹងសិទ្ធិជាមនុស្សរបស់អាត្មាភាពយើងខ្ញុំ និងសិទ្ធិជាជនជាតិដើមលើទឹកដីកម្ពុជាក្រោម ។ ព្រះសង្ឃខ្មែរក្រោមត្រូវបានហាមឃាត់មិនឲ្យធ្វើដំណើរដោយសេរី ពីកន្លែងមួយទៅកន្លែងមួយទៀតទាំងក្នុងប្រទេស ឬ ក្រៅប្រទេស ។ ប្រជាជាតិខ្មែរក្រោមនៃអាត្មាភាពយើងខ្ញុំ បានបាត់បង់អស់ហើយនូវសិទ្ធិជាសារវន្តរបស់ខ្លួន។ ភាពទទួលបាននូវការសិក្សាអប់រំថ្នាក់ខ្ពស់ ការផ្គត់ផ្គង់ថវិកាធ្វើអាជីវ–កម្ម សន្តិសុខសង្គម ថ្នាំសង្កូវ សេវាសុខភាព មន្ទីរពេទ្យ គឺនៅមានកម្រិតទាបខ្លាំងណាស់សម្រាប់ប្រជាជាតិខ្មែរក្រោម ។

កិច្ចប្រជុំក្នុងឱកាសនេះ គឺជាព្រឹត្តការណ៍ប្រវត្តិសាស្ត្រមួយសម្រាប់ព្រះសង្ឃខ្មែរក្រោម និង ពុទ្ធសាសនិកជនខ្មែរក្រោម ។ អាត្មាភាពយើងខ្ញុំ សូមអំពាវនាវដល់អង្គការសហប្រជាជាតិ សហគមន៍អន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ដែលមានវត្តមាននៅទីនេះជួយធ្វើជាសាក្សីនូវការពិត អំពីជំលោះទាស់ទែងគ្នាដ៏យូរអង្វែងរវាងប្រជា–ជាតិខ្មែរក្រោម និង ជនជាតិវៀតណាម ។ ឥឡូវនេះ អាត្មាភាពយើងខ្ញុំ ស្នើសុំនូវការសហប្រតិបត្តិការរបស់អស់លោកអ្នក ដើម្បីជួយស្វែងរកយុត្តិធម៌ សេរីភាព និងដើម្បីបញ្ចប់នូវទុក្ខវេទនាដែលមាននៅកម្ពុជាក្រោម ។

***សូមថ្លែងអំណរគុណ ចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់អស់លោកអ្នក*** !

*(សេចក្តីថ្លែងការណ៍នេះនៅមានបន្តទៅព្រឹត្តិបត្រលេខក្រោយទៀត)*

# សេចក្តីប្រកាសព័ត៌មានស្តីអំពី បាតុកម្មតវ៉ានឹងទស្សនកិច្ចរបស់នាយករដ្ឋមន្ត្រីវៀតណាម

*កាលពីថ្ងៃទី ១១ មិថុនា ២០០៥ សហព័ន្ធខ្មែរកម្ពុជាក្រោម បានធ្វើសេចក្តីប្រកាសព័ត៌មានមួយ ទាក់ទងទៅដំណើរទស្សនៈកិច្ចលើកដំបូងនៃមេដឹកកំពូលរបស់យួន ទៅកាន់សហរដ្ឋអាមេរិក ដែលមានខ្លឹមសារដូចតទៅ ៖*

*នៅពេលដែលនាយករដ្ឋមន្ត្រីវៀតណាម ផាន់ វ៉ាន់ខាយ មកធ្វើទស្សនកិច្ចលើកដំបូងនៅរដ្ឋធានីសហរដ្ឋអាមេរិក ថ្ងៃទី ២១ មិថុនា ២០០៥ សហព័ន្ធខ្មែរកម្ពុជាក្រោម នឹងធ្វើបាតុកម្មតវ៉ាមួយនៅរដ្ឋធានីវ៉ាស៊ីនតោនដើម្បីបញ្ចេញមតិអំពីការរំលោភសិទ្ធិមនុស្ស ដែលអនុវត្តដោយរដ្ឋាភិបាលកុម្មុយនិស្តវៀតណាម ។*

***វេលា*** *៖ ម៉ោង ១០ ព្រឹក ដល់ ម៉ោង ២ រសៀល*

***ទីកន្លែង*** ៖ Freedom Plaza, Pennsyvannia Ave.

(*នៅចន្លោះផ្លូវ* 13rd st *និង* 14th st) Washington DC

***សូមទាក់ទង ៖***

*លោក ត្រាន់ ម៉ានរិន -ទូរស័ព្ទលេខ (២១៥) ៧៤៥ ៣២២៥*

*លោក ហាង វឿង -ទូរស័ព្ទលេខ (២១៥) ២៩២ ២៨៦៣*

*លោក ដាំង វណ្ណី -ទូរស័ព្ទលេខ (៨០៤) ៧៤៤ ៣៨៥៩*

*ឬ (៨០៤) ៣០១ ៤៤០៨*

*សហព័ន្ធខ្មែរកម្ពុជាក្រោម តំណាងឲ្យខ្មែរក្រោមដែលជាជនជាតិដើមនៅដែនដីសណ្តទន្លេមេគង្គ ។ ថ្វីបើខ្មែរក្រោមមានចំនួនច្រើនលាននាក់ និងមានវប្បធម៌ទំនៀមទម្លាប់ ហើយនិងភាសារបស់ខ្លួនក៏ដោយ ក៏ពិភពលោកនៅដឹងតិចអំពីខ្មែរក្រោមតិចតួចណាស់ ។ ក្នុងប្រវត្តិសាស្ត្រ រដ្ឋាភិបាលវៀតណាមតែងតែបន្តនូវផែនការរបស់គេ គឺធ្វើយ៉ាងណាឲ្យខ្មែរក្រោមឋិតក្នុងភាពក្រីក្រ និងល្ងង់ខ្លៅ ដែលនាំឲ្យខ្មែរក្រោមមិនអាចនិយាយតវ៉ាប្រឆាំងនឹងអ្នកជិះជាន់របស់ខ្លួនបានឡើយ ។ ចាប់ពីឆ្នាំ ១៩៧៥ មក កាល ដែលរបបកុម្មុយនិស្តត្រួតត្រាប្រទេសវៀត-ណាមទាំងមូល ក្រុងហាណូយបានប្រើអានុភាពរបស់ខ្លួន ដើម្បីបំភិតបំភ័យខ្មែរក្រោម និងជនជាតិដើមដទៃទៀត ។ វត្តអារាមជាច្រើនបានក្លាយទៅជាពន្ធនាគារ ។ ចំពោះជនណាមួយហ៊ានទិទៀនអំពីការរំលោភសិទ្ធិមនុស្សរបស់រដ្ឋាភិបាលនោះ គឺត្រូវបានចាត់ទុកថាជាភ្នាក់-ងារយកការណ៍សម្ងាត់អាមេរិក* (CIA) *ហើយត្រូវទទួលទណ្ឌកម្មយ៉ាងឃោរឃៅ ។ ជនរងគ្រោះជាច្រើនត្រូវបានស្លាប់ដោយការចោទប្រកាន់នោះ ។ ក្នុងរយៈកាលប៉ុន្មានខែកន្លងមកនេះ សហព័ន្ធខ្មែរកម្ពុជាក្រោមបានធ្វើយុទ្ធការស្វែងរកការគាំទ្រពីសំណាក់សហគមន៍អន្តរជាតិ ។ រដ្ឋអំណាចវៀតណាមបានឆ្លើយតបដោយការចាប់ចង និងធ្វើការចោទប្រកាន់លើខ្មែរក្រោមស្ទួតត្រង់ទូទាំងភាគខាងត្បូងវៀតណាម ។ ខ្មែរក្រោមរាប់រយនាក់បានរត់គៀសខ្លួនពីភូមិកំណើត មកជ្រកកោននៅព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃឡង់ ។ ក្រោមការត្រួតត្រារបស់វៀតណាម ខ្មែរក្រោមត្រូវរងគ្រោះ ដែលយើងខ្ញុំសូមលើកយកស្ថានភាពថ្មីៗ ជាគោល មកជម្រាប់ជូនដូចតទៅ ៖*

*-រដ្ឋាភិបាលវៀតណាម បន្តការធ្វើទុក្ខបុកម្នេញលើព្រះពុទ្ធ-សាសនា ។ ការគោរពប្រណិប័តណ៍សាសនាត្រូវនៅក្រោមការត្រួតត្រារបស់រដ្ឋាភិបាល ។*

-ខ្មែរក្រោមធ្លាក់ខ្លួនក្រីក្រ ដោយសាររដ្ឋាភិបាលវៀតណាមរឹបអូសយកដីស្រែ និងទ្រព្យសម្បត្តិ ។

-គ្មានការយកចិត្តទុកដាក់ដល់សុខុមាលភាព ធ្វើឲ្យខ្មែរក្រោមរាប់ពាន់នាក់រងគ្រោះដោយជំងឺពិការភ្នែក ។

-កូនចៅខ្មែរក្រោមមិនបានរៀនសូត្រខ្ពស់ ។ ភាសាខ្មែរមិនបានដាក់បញ្ចូលនៅក្នុងកម្មវិធីសិក្សា ។

-រដ្ឋអំណាចវៀតណាមបន្តការអនុវត្តផែនការថ្មី បំភិតបំភ័យ ចោទប្រកាន់គ្មានហេតុផល និងចាប់ដាក់ពន្ធនាគារចំពោះប្រជាពលរដ្ឋខ្មែរក្រោមស្លូតត្រង់ ។

-សេរីភាពជាមូលដ្ឋាន ដូចជាសេរីភាពក្នុងការបញ្ចេញមតិ ជួបជុំគ្នា ត្រូវហាមប្រាម ។

ក្នុងនាមខ្មែរក្រោម សហព័ន្ធខ្មែរកម្ពុជាក្រោម សូមអំពាវនាវដល់រដ្ឋាភិបាលទាំងអស់ អង្គការអន្តរជាតិ ភ្នាក់ងារសារព័ត៌មានទូទាំងសកលលោកមេត្តាដាក់គំនាបលើរដ្ឋាភិបាលវៀតណាមដូចខាងក្រោម ៖

-បញ្ឈប់ជាបន្ទាន់នូវសកម្មភាពបំភិតបំភ័យ គំរាមកំហែងមកលើខ្មែរក្រោម ។

-អនុញ្ញាតឲ្យអ្នកសង្កេតការណ៍អន្តរជាតិ ពិនិត្យមើលតាមភូមិស្រុកដែលខ្មែរក្រោមរស់នៅ ។

-គោរពសិទ្ធិមនុស្សជាមូលដ្ឋាន ចំពោះរាល់ប្រជាពលរដ្ឋវៀត-ណាម ។

-ចាត់តាំងឲ្យមានក្រុមវេជ្ជបណ្ឌិត នៃអង្គការសុខភាពពិភពលោក អ្នកវិទ្យាសាស្ត្រ និងក្រុមការពារសិទ្ធិមនុស្សធ្វើការសិក្សា និងស៊ើបអង្កេតនូវមូលហេតុនៃរោគរាតត្បាត ព្រមទាំងជំងឺពិការភ្នែកដែលខ្មែរក្រោមរាប់ពាន់នាក់ នៅខេត្តឃ្លាំង និងខេត្តពលលាវកំពុងទទួលរង ។

-ត្រូវប្រគល់ដីស្រែ និងទ្រព្យសម្បត្តិ ដែលរដ្ឋាភិបាលវៀត-ណាមរឹបអូសយក ជូនទៅម្ចាស់ដើមវិញ ៕

VOKK

# សង្គ្រាមខ្មែរ–យួន នៅក្នុងអង្គការសហប្រជាជាតិ

*សេចក្ដីប្រកាសព័ត៌មាន របស់គណបក្សចម្រើននិយម ពហុជាតិសាសន៍*



ទិដ្ឋភាពនៃវេទិកាអង្គការសហប្រជាជាតិ ស្ដីអំពីបញ្ហាជនជាតិដើម

នៅក្នុងវេទិកាអចិន្ត្រៃយ៍ នៃអង្គការសហប្រជាជាតិ ស្ដីអំពីជនជាតិដើមឆ្នាំនេះ គេសង្កេតឃើញមានជនជាតិយួនទៅចូលរួម និងថ្លែងសុន្ទរកថាវាយប្រហារមកលើជនជាតិខ្មែរ ម៉ុងតាញ៉ា និង ជនជាតិភាគតិចដទៃទៀត ។ គឺគេកំពុងតែពង្រីកគោលនយោបាយប្រឆាំងជនជាតិភាគ ក៏ដូចជាជនជាតិដើម មិននៅត្រឹមតែខ័ណ្ឌសីមាប្រទេសយៀកណាមប៉ុណ្ណោះទេ គឺពង្រីកទូទាំងពិភពលោក ។

គណបក្សចម្រើននិយម ពហុជាតិសាសន៍ (The Trans-national Radical Party) ជាអង្គការអន្តរជាតិមួយ មានបេសកកម្មប្រហាក់ប្រហែលនឹងអង្គការ យូអិនភីអូ បានធ្វើសេចក្ដីប្រកាសព័ត៌-មានកត់សម្គាល់ថា ប្រទេសយៀកណាម បានថ្លែងនៅក្នុងប្រធានបទមួយពាក់ព័ន្ធទៅនឹងការការពារសិទ្ធិមនុស្ស សេរីភាពជាសារវ័ន្តនៃជនជាតិដើម បានស្នើឲ្យអង្គវេទិកាចាត់វិធានការ ចំពោះសហព័ន្ធខ្មែរកម្ពុជាក្រោម សហគមព្រះសង្ឃខ្មែរកម្ពុជាក្រោម និងមូលនិធិម៉ុងតា-ញ៉ា ទន្ទឹមនឹងសំដីមើលងាយមើលថោកជនជាតិដើម ។ សេចក្ដីប្រកាសព័ត៌មានរបស់គណបក្សចម្រើននិយមពហុជាតិសាសន៍ បានបញ្ជាក់ថា ការណ៍នេះបានបង្ហាញឲ្យឃើញនូវការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ និងការប្រកាន់រើសអើងពីសំណាក់រដ្ឋាភិបាលយួន ។ល។

សូមរំឭកថា រដ្ឋាភិបាលយួនក៏ធ្លាប់ចោទប្រកាន់គណបក្សចម្រើននិយមពហុជាតិសាសន៍នេះកាលពី ២ ឆ្នាំមុនដែរ ព្រមជាមួយការចោទប្រកាន់លោក ក្យ កុក ថាជាភេរវជន ។ ហើយគេបានស្នើឲ្យក្រុមប្រឹក្សា ECOSOC នៃអង្គការសហប្រជាជាតិ ឲ្យដកទូនាទីជាទីប្រឹក្សារបស់គណបក្សចម្រើននិយកពហុជាតិសាសន៍ ប៉ុន្តែយួនត្រូវបរាជ័យកាលពីខែកក្កដា ២០០៤ ដោយសមាជិកអង្គការសហ-ប្រជាជាតិភាគច្រើនគាំទ្រគណបក្សនេះ ។

ដោយនយោបាយចាត់ទុកជនជាតិដើម និងជនជាតិភាគតិចជាក្រុមប្រតិកិរិយា យួនមិនត្រឹមតែប្រឆាំងជនជាតិដើម និងជនជាតិភាគតិចនៅក្នុងស្រុក គេថែមទាំងមិនទទួលស្គាល់ ហើយប្រឆាំងអង្គការចាត់តាំងនៃក្រុមជន ដែលគេហៅថា "ប្រតិកិរិយា" នេះនៅលើឆាកអន្តរជាតិ ហើយថែមទាំងប្រឆាំងនឹងអង្គការអន្តរជាតិណាដែលគាំទ្រជនជាតិដើម និងជនជាតិភាគតិច ៕

# ពិធីអបអរសាទរសហព័ន្ធខ្មែរកម្ពុជាក្រោម ក្នុងវេទិកាអង្គការសហប្រជាជាតិ



*ឥស្សរជនខ្មែរ ក្នុងពិធីអបអរសាទរសហព័ន្ធខ្មែរកម្ពុជាក្រោម*

*មិត្តសមាគមខ្មែរកម្ពុជាក្រោម សមាគមព្រះសង្ឃខ្មែរកម្ពុជា–ក្រោម និងសម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោម បានប្រារព្ធពិធីអបអរសាទរគណៈប្រតិភូសហព័ន្ធខ្មែរកម្ពុជាក្រោម នៅក្នុងវេទិកាអចិន្ត្រៃយ៍អង្គការសហប្រជាជាតិស្តីអំពីបញ្ហាជនជាតិដើម នាទីក្រុងញូវយ៉ក ។ ពិធីនេះរៀបចំឡើងចាប់ពីម៉ោង ១៤ ដល់ ១៧ និង ៣០ នាទី ថ្ងៃទី ២១ ឧសភា នៅទីធ្លាវត្តសាមគ្គីរង្សី រាជធានីភ្នំពេញ ដោយមានការចូលរួមគាំទ្រអបអរសាទរពីសំណាក់ប្រជារាស្ត្រខ្មែរក្រោមពីគ្រប់មជ្ឈដ្ឋាន ប្រមាណជាង ២០០ ប្រកបដោយបរិយាកាសឱឡារឹកក្រៃលែង ។*

ថ្លែងក្នុងសុន្ទរកថាបើកអង្គពិធីនេះ ដោយលោក សាំង សារ៉េត ប្រធានគណៈកម្មការរៀបចំអង្គពិធី និងជានាយកប្រតិបត្តិមិត្តសមាគមខ្មែរកម្ពុជាក្រោម ។

ក្រៅពីកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះភ្ញៀវ ដែលបានចូលរួម និង ប្រសិទ្ធិពរជ័យដល់គណៈប្រតិភូសហព័ន្ធក្នុងដំណើរចូលទៅកាន់វេទិកាអចិន្ត្រៃយ៍ជនជាតិដើម ព្រមទាំងការដឹងគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលជានិច្ចកាលជួយគាំពារដល់ខ្មែរកម្ពុជាក្រោម ។

លោក សាំង សារ៉េត បានគូសបញ្ជាក់ពីគោលជំហរនៃអង្គពិធីនេះដូច្នេះថា ៖ វត្ថុបំណងរបស់យើងទាំងអស់គ្នា ដែលកំពុងស្តែងចេញក្នុងឱកាសនេះ នៅទីនេះ គឺជាសក្ខីកម្មរបស់បងប្អូនខ្មែរកម្ពុជាក្រោមគ្រប់មជ្ឈដ្ឋានក្នុងការសំដែងមោទនភាពខ្លួន ដើម្បីអបអរសាទរចំពោះគណៈប្រតិភូរបស់សហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោក ដែលក្នុងពេលនេះ ម៉ោងនេះ នាទីនេះ វិនាទីនេះ កំពុងតែតំណាងឲ្យយើងទាំងអស់គ្នាបញ្ចេញនូវសកម្មភាព និងកាតព្វកិច្ចថ្លែងប្រាប់ពិភពលោកអំពីគោលបំណង និងការស្រេកឃ្លានរបស់ប្រជាជាតិយើងលើវេទិកាអង្គការសហប្រជាជាតិ នាទីក្រុងញ៉ូវយ៉កនៃសហរដ្ឋអាមេរិក ។

នៅចំពោះមុខប្រជាជាតិខ្មែរកម្ពុជាក្រោម និង ភ្ញៀវដែលកំពុងចូលរួមនាពិធីអបអរសាទរនោះ បន្ទាប់ពីសុន្ទរកថាបើកអង្គពិធីរបស់លោក សាំង សារ៉េត មក លោក តាំង សារៈ តំណាងសហព័ន្ធខ្មែរកម្ពុជាក្រោមប្រចាំព្រះរាជាណាចក្រកម្ពុជា បានឡើងថ្លែងសុន្ទរ–កថាអរគុណ ចំពោះព្រះសង្ឃ និងជនរួមជាតិ ព្រមទាំងភ្ញៀវទាំងអស់ដែលបានចូលរួមក្នុងអង្គពិធីអបអរសាទរនេះ ហើយនិងបានពាំនាំនូវសេចក្តីសួរសុខទុក្ខ និងប្រសិទ្ធិពរពីថ្នាក់ដឹកនាំសហព័ន្ធខ្មែរកម្ពុជា–ក្រោម មានលោកអធិបតីសហព័ន្ធ តោ គឹម ថុង ជាអាទិ៍ ជូនដល់ជនរួមជាតិទាំងអស់ ទាំងព្រះសង្ឃ ទាំងគ្រហស្ថ ដែលកំពុងជួយការងារសហព័ន្ធនិងមានការឈឺឆ្អាលចំពោះជោគវាសនាជាតិមាតុភូមិនោះ”។

ក្នុងសុន្ទរកថានេះដែរ លោក តាំង សារៈ បានថ្លែងរំឭកមកវិញនូវសមិទ្ធផល ដែលសហព័ន្ធខ្មែរកម្ពុជាក្រោមទទួលបានដោយសកម្មភាពសន្តិវិធី និងអហិង្សា ហើយលោកក៏បានសំដែងនូវសេចក្តីសង្ឃឹមយ៉ាងមុតមាំ ដូច្នេះ ៖ ឆ្លងតាមរយៈការចូលរួមរបស់គណៈ–ប្រតិភូសហព័ន្ធខ្មែរកម្ពុជាក្រោម នៅក្នុងវេទិកាអង្គការសហប្រជាជាតិនាពេលនេះ យើងសង្ឃឹមថាខ្មែរកម្ពុជាក្រោម នឹងជៀសផុតពីភពខ្មៅងងឹតមួយចំណែក ដែលខ្មែរក្រោមធ្លាប់តែបានទទួលនូវការមើលងាយការរើសអើង ការបន្តវិនាសកម្មផ្សេង ៗ ដែលរដ្ឋាភិបាលវៀតណាមធ្លាប់ធ្វើមកលើប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម ដូចជាការសម្លាប់យ៉ាងសាហាវព្រៃផ្សៃ អមនុស្សធម៌ ក្នុងអំឡុងឆ្នាំ ១៩៤៥, ការរំលាយពុទ្ធ–សាសន៍ខ្មែរ ក្នុងអំឡុងឆ្នាំ ១៩៦៩, ការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរមកលើបងប្អូនខ្មែរកម្ពុជាក្រោមក្នុងអំឡុងឆ្នាំ១៩៨៥–៨៦, ក្នុងករណីកាសេ ៥០ និងការព្យាយាមរំលោភលើសិទ្ធិជាមូលដ្ឋានរបស់ខ្មែរកម្ពុជាក្រោមតាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ននិងតទៅអនាគតទៀតនោះ ។

បន្ទាប់ពីសុន្ទរកថារបស់លោក តាំង សារៈ មក លោក ជៀង ដែល ដែលជាចាស់ព្រឹទ្ធាចារ្យខ្មែរកម្ពុជាក្រោមមួយរូប ដែលពោរពេញដោយឧត្តមគតិជាតិនោះ បានថ្លែងចំណាប់អារម្មណ៍កោតសរសើរនូវវីរភាពបន្តវេនដ៏អង់អាចក្លាហាន និងជោគជ័យដ៏ត្រចះត្រចង់របស់កុលបុត្រ–កុលធីតាខ្មែរក្រោមគ្រប់រូប និងលោកបានដាស់ស្មារតីដូច្នេះ សូមព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនជនរួមជាតិកុំភ្លេចថា “នេះមិនមែនជាជោគជ័យដែលយើងត្រូវស្កប់ស្កល់នោះទេ ព្រោះការតស៊ូរបស់យើងនៅវែងឆ្ងាយ ត្រូវប្រមូលបញ្ញាញាណតស៊ូ អត់ធ្មត់ ឆ្លងកាត់នូវឧបសគ្គធំ ៗ ជាច្រើនទៀត ដើម្បីទទួលបានសិទ្ធិជាម្ចាស់ទឹកដីសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង នៅលើមាតុភូមិកម្ពុជាក្រោមជាទីស្នេហារបស់យើង ។ ខ្ញុំព្រះករុណាខ្ញុំក៏សូមអំពាវនាវដល់បងប្អូនខ្មែរកម្ពុជាក្រោមគ្រប់មជ្ឈដ្ឋាន សូមកុំបង្កសកម្មភាពណាមួយនាំឲ្យបន្តុចបង្អាក់រារាំងដំណើរការតស៊ូរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម ឲ្យ

សោះ បើពុំដូច្នោះទេនឹងត្រូវខូចឈ្មោះចំពោះមុខប្រវត្តិសាស្ត្រជាតិជាក់ជាពុំខានឡើយ ។

ឆ្លៀតក្នុងឱកាសនេះដែរ លោក អ៊ុយ សុភ័ក្ត្រ អគ្គលេខាធិការមិត្តសមាគមខ្មែរកម្ពុជាក្រោម បានអាននូវញត្តិថ្កោលទោសរបស់ប្រជាជាតិខ្មែរក្រោម ជូនចំពោះឯកឧត្តម Kofi Annan អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ឯកឧត្តម George W. Bush ប្រធានាធិបតីនៃសហរដ្ឋអាមេរិក ឯកឧត្តម Josep Borrell Fotelles ប្រធានសភានៃសហគមន៍អឺរ៉ុប ស្តីពីអំពើប្រល័យពូជសាសន៍របស់យួនមកលើជាតិមាតុភូមិខ្មែរកម្ពុជាក្រោម ចាប់តាំងពីឆ្នាំ ១៩៤៥ រហូតមក ។

ចំណែកបងស្រី លី ធីឡុង និងបងស្រី ឡឹម ធីថា ដែលបានអញ្ជើញមកពីខេត្តឃ្លាំង ដើម្បីចូលរួមកក្នុងពិធីអបអរសាទរនេះដែរ បងស្រីទាំងពីរ បានសម្តែងនូវសមានចិត្តត្រេកអរយ៉ាងក្រៃលែងនូវការចូលរួមរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម ក្នុងវេទិកាអចិន្ត្រៃយ៍អង្គការសហប្រជាជាតិស្តីអំពីបញ្ហាជនជាតិដើមនេះ ។

ឯភិក្ខុ ថាច់ ភព្វ ព្រះអង្គទើបតែភៀសខ្លួនថ្មី ៗ ទៅពីខេត្តព្រះត្រពាំង បានមានថេរដីកាឲ្យដឹងថា ៖ "អាត្មាត្រេកអរខ្លាំងណាស់រកវត្ថុអ្វីមកប្រៀបផ្ទឹមពុំបានឡើយ ដែលបានមកចូលរួមពិធីអបអរសាទរយ៉ាងឱឡារិកនេះ ។ ចំណែកនៅកម្ពុជាក្រោម យើងមិនអាចប្រារព្ធពិធីបែបនេះបានទេ សូម្បីតែការផ្សព្វផ្សាយព្រឹត្តិបត្រកម្ពុជាក្រោម ឬ ស៊ីឌីកាសែតចម្រៀងខ្មែរក្រោម ក៏យើងធ្វើដោយលួចលាក់អាថ៌កំបាំងបំផុត ។

ចុងបញ្ចប់នៃកម្មវិធី ព្រះតេជគុណ យឿង សិន ប្រធានសមាគមព្រះសង្ឃខ្មែរកម្ពុជាក្រោម និងជាព្រះចៅអធិការវត្តសាមគ្គីរង្សី បានថ្លែងនូវសោមនស្សរកថា និងអភ័យកថាចំពោះភ្ញៀវដែលបានចូលរួមទាំងអស់ ។ បន្ទាប់ពីព្រះសង្ឃស្វាធ្យាយធម៌បង្សុកូលជូនបុព្វការីជនដែលបូជាជីវិតដើម្បីជាតិមាតុភូមិរួចមក ភ្ញៀវកិត្តិយសបានចូលរួមពិសាភោជនាហារជុំគ្នា ក្នុងកាយវិការរាក់ទាក់រកគ្នាជាភាតរៈ និងរំភើបរីករាយក្រៃលែង។ កម្មវិធីអបអរសាទរគណៈប្រតិភូសហព័ន្ធខ្មែរកម្ពុជាក្រោម បានចប់សព្វគ្រប់នៅវេលាម៉ោង ១៧ និង ៣០ នាទី ៕

VOKK




ក្រុមឆៃយ៉ាំសាលាឆទានខ្មែរកម្ពុជាក្រោម អបអរសាទរសហព័ន្ធខ្មែរកម្ពុជាក្រោម




**-វិទ្យុសំឡេងកម្ពុជាក្រោម** *ជាសំឡេងរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម ផ្សាយចេញពីក្រុងវ៉ាស៊ីនតោនរដ្ឋធានី នៃសហរដ្ឋអាមេរិក សម្រាប់បម្រើដល់ប្រិយមិត្តអ្នកនិយមស្តាប់ការផ្សាយរបស់វិទ្យុយើងខ្ញុំ ។*

**-កម្មវិធីផ្សាយ** ៖ *ផ្សាយក្នុងមួយសប្តាហ៍ម្តង រៀងរាល់ថ្ងៃអង្គារ ចាប់ពីម៉ោង ៩ ដល់ម៉ោង ១០ យប់ម៉ោងនៅកម្ពុជាក្រោម តាមកម្ពស់រលកធាតុអាកាសខ្លី ១៥.៦៩០ គីឡូហឺត ។*

*-ប្រិយមិត្ត ក៏អាចបើកស្តាប់បានគ្រប់ពេល តាមរយៈគេហទំព័រ* www.khmerkrom.org/radio ។

ប្រសិនបើអស់លោក លោកស្រី អ្នកនាងកញ្ញា បងប្អូនជនរួមជាតិចង់ដឹងបន្ថែមនៅព្រឹត្តិការណ៍ និងព័ត៌មានថ្មី ៗ របស់សហព័ន្ធខ្មែរកម្ពុជាក្រោម សូមចូលទៅក្នុងវ៉ែបសាយន៍ www.khmerkrom.net និងចង់ដឹងអំពីរបៀបធ្វើម្ហូប និងមុខម្ហូបរបស់ខ្មែរកម្ពុជាក្រោម សូមចូលទៅវ៉ែបសាយន៍ www.khmerkromre.com ។

# អាជ្ញាធរយួនខេត្តឃ្លាំងរំលោភបំពានមកលើសមណនិស្សិត

*អាជ្ញាធរយួនក្នុងសាលាបាលីជាន់ខ្ពស់ យួនហៅថាសាលាបាលីណាមបូ ដែលមានទីតាំងក្នុងបរិវេណវត្តឃ្លាំង នាទីរួមខេត្តឃ្លាំង កម្ពុជាក្រោម បានប្រើអំណាចកុម្មុយនិស្តរបស់ខ្លួន រំលោភបំពានមកលើសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោម មានករណីហាមមិនឲ្យស្តាប់វិទ្យុ ហាមមិនឲ្យបញ្ចេញមតិ និងប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិតជាដើម ។ រឿងនេះបានកើតឡើង តាំងពីឆ្នាំ ២០០៣ រហូតមក តែទើបតែបែកខ្ញាយប៉ុន្មានថ្ងៃមកនេះដោយមានសមណនិស្សិតមួយចំនួន បានភៀសខ្លួនទៅជ្រកកោនក្នុងព្រះរាជាណាចក្រកម្ពុជា ហើយប្តឹងដល់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ។*

សាលាបាលីណាមបូ ដែលខ្មែរនិយមហៅថាសាលាបាលីជាន់ខ្ពស់ បានកើតឡើងតាំងពីឆ្នាំ ១៩៩៣ ក្រោមការផ្តួចផ្តើមឡើងដោយឥស្សរជនខ្មែរក្រោមមួយចំនួនមាន លោកមហា វិញ គឿង ជាប្រមុខ ។

សាលាបាលីជាន់ខ្ពស់ មានទីតាំងជាប់នឹងវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យរងដែនកូសាំងស៊ីន ពីអតីតកាល ស្ថិតក្នុងវត្តឃ្លាំង នាទីរួមខេត្តឃ្លាំង ។

សាលាបាលីជាន់ខ្ពស់ ជាមជ្ឈមណ្ឌលពុទ្ធិកវិទ្យាល័យតែមួយគត់នៅដែនដីកម្ពុជាក្រោម ហើយបច្ចុប្បន្ន មានព្រះមហាថេរ យឿង ញើង ជានាយកសាលា ព្រះមហាថេរ តាំង ណូ ជានាយករងទី ១ និងលោក ឡឹម វី ជានាយករងទី ២ ។

តាមព្រះថេរដីការបស់ព្រះមហាថេរ តាំង ណូ បានឲ្យដឹងថា "ក្នុងមួយជំនាន់ ៗ សាលានេះអាចទទួលសិស្សតែ ៥០ អង្គប៉ុណ្ណោះ ហើយសិស្សទាំងនេះ ត្រូវបានបញ្ជូនមកពីគ្រប់ខេត្ត-ក្រុងនៃដែនដីកម្ពុជាក្រោម ។

ឯលោក ឡឹម វី បានបង្ហាញពីកម្មវិធីសិក្សាត្រួស ៗ ដូច្នេះ "កម្មវិធីភាសាខ្មែរ និងបាលី គឺក្នុងមួយសប្តាហ៍បង្រៀនពីរពេល មាន ៨ ម៉ោង ។ កម្មវិធីភាសាខ្មែរ បង្រៀនជាពិសេស គឺមុខវិជ្ជាតែងនិពន្ធកំណាព្យ ឯភាសាបាលី គឺបង្រៀនប្រែគម្ពីរមង្គលលត្ថទីបនី ។ ចំណែកនៅសល់ ៤ ពេលទៀត ជាកម្មវិធីចំណេះដឹងទូទៅ បង្រៀនដោយភាសាយួន ដែលមាន គណិតវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា និងទស្សនវិទ្យានៃលិទ្ធិកុម្មុយនិស្តជាដើម ។

តាមសង្ឃដីការបស់ភិក្ខុ យ៉ាញ់ ឍាគ ជាសមណនិស្សិតនិមន្តមកពីខេត្តក្រមួនស បានត្អូញថា មើលរូបភាពខាងក្រៅ គេឃើញថា យួនប្រគល់សិទ្ធិឲ្យខ្មែរគ្រប់គ្រងសាលាបាលីជាន់ខ្ពស់នេះ ទាំងស្រុង តាមការពិត មិនដូចការមើលឃើញនោះទេ គឺថ្នាក់ដឹកនាំសាលានេះ ស្ថិតនៅក្រោមបញ្ជាដាច់ខាតរបស់កុម្មុយនិស្តយួននៅពីក្រោយខ្នង ។

ភិក្ខុ ថាច់ តឹម ជាសមណនិស្សិតជំនាន់ទី ២ បានមានថេរដីកាថា សមណនិស្សិតគ្រប់ជំនាន់ ស្ទើរតែគ្រប់ព្រះអង្គ មិនពេញចិត្តនឹងកម្មវិធីសិក្សា ដែលច្រើនតែវិញ្ញាសាយួននោះទេ ហើយបាននាំគ្នាតវ៉ាជាច្រើនលើកច្រើនសារ តែមិនដែលទទួលបានផលល្អឡើយ គឺបានទទួលមកវិញ នូវការស្តីបន្ទោសពីថ្នាក់ដឹកនាំសាលាតែប៉ុណ្ណោះ ធ្វើឲ្យសមណនិស្សិតខ្លះធុញទ្រាន់ ហើយក៏បោះបង់ការសិក្សាទាំងកណ្តាលទី ។

សមណនិស្សិត ចៅ សំអឿន និមន្តមកពីខេត្តមាត់ជ្រូក បានថ្លែងនូវទុក្ខលំបាករបស់សមណនិស្សិតសាលានេះថា "ថ្នាក់ដឹកនាំសាលា បានហាមមិនឲ្យសមណនិស្សិតជួបជុំគ្នានៅទីស្ងាត់លើសពីបីអង្គឡើងទៅ ហាមមិនឲ្យស្តាប់វិទ្យុបរទេស មានវិទ្យុអាមេរិក (VOA) អាស៊ីសេរី និងវិទ្យុសំឡេងកម្ពុជាក្រោម ជាដើម និងហាមមិនឲ្យអានមិនឲ្យទុកនូវសៀវភៅ ឬ ឯកសារស្តីពីការជិះជាន់របស់អាណានិគមយួនមកលើជាតិមាតុភូមិកម្ពុជាក្រោម មានសៀវភៅក្រោមចំណងជើង "ទុក្ខខ្មែរក្រោម" ដែលចងក្រងឡើងដោយលោក ថាច់ សិរ នៅអាមេរិកជាដើម មិនតែប៉ុណ្ណោះសោត សូម្បីតែចម្រៀងខ្មែរ ដែលច្រៀងឡើងថ្លែងពីទុក្ខសោក មនោសញ្ចេតនា ភូមិស្រុកខ្មែរក្រោម ក៏ពុំឲ្យស្តាប់ និងពុំឲ្យរក្សាទុកនូវ CD ឬ កាសែតទាំងនោះផងដែរ ។

ចំណែកសមណនិស្សិត ថាច់ សុខុម ដែលទើបតែភៀសខ្លួនទៅទីក្រុងភ្នំពេញ ហើយស្ថិតនៅក្រោមការការពារដោយឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ព្រះអង្គរៀបរាប់ថា "នៅក្នុងអំឡុងឆ្នាំ ២០០៤ កន្លងមក មន្ត្រីស្ថានទូតអាមេរិកប្រចាំវៀតណាម មានបំណងចូលមកសួរសុខទុក្ខនិស្សិតនៅសាលាបាលីខ្មែរក្រោម តែត្រូវថ្នាក់ដឹកនាំសាលារារាំង ដោយកុហកមន្ត្រីស្ថានទូតនោះថា និស្សិតទាំងអស់ត្រូវបានឈប់សម្រាកមួយខែ គ្មានអង្គណាមួយស្ថិតក្នុងសាលានេះទេ ។ មិនតែប៉ុណ្ណោះ សព្វថ្ងៃ និស្សិតក្នុងសាលានេះ ត្រូវបានហាមឃាត់មិនឲ្យប្រាស្រ័យទាក់ទងនឹងជនបរទេសឡើយ សូម្បីជននោះជាទេសចរក៏ដោយ ហើយនិស្សិតទាំងអស់ក៏ត្រូវហាមឃាត់មិនឲ្យប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិតទៀតផង" ។

សមណនិស្សិតថាច់ សុខុម បានបំភ្លឺបន្ថែមថា "ការណ៍ដែលគេមិនឲ្យនិស្សិតប្រាស្រ័យទាក់ទងនឹងជនបរទេស ព្រោះគេខ្លាចជនទាំងនោះ ជ្រាបនូវអំពើដែលគេកំពុងរំលោភបំពានមកលើនិស្សិត និងប្រជាជាតិខ្មែរកម្ពុជាក្រោម" ។

រីឯការណ៍ដែលគេហាមប្រាម មិនឲ្យនិស្សិតប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណិតនោះ ព្រោះគេខ្លាចនិស្សិតទាំងអស់ មានទំនាក់ទំនងនឹងអ្នកក្រៅប្រទេស ឬ ផ្តល់ព័ត៌មានអំពីពុតត្បុត ការរំលោភសិទ្ធិ ការបំពារបំពានមកលើប្រជាជាតិខ្មែរកម្ពុជាក្រោមនោះឯង ៕

VOKK

# អាជ្ញាធរយួនឃុំចូវឡាំងរុះរើសាលា និងកាប់បំផ្លាញដើមឈើវត្តជីភ្លេងក្រោម

*តាំងពីឆ្នាំ ១៩៧៥ ពេលឡើងកាន់អំណាចនៅភូមិភាគខាងត្បូងមក អាជ្ញាធរកុម្មុយនិស្តយួនបានរឹបអូស និងរុះរើវត្តអារាមខ្មែរ បំផ្លាញមរតកវប្បធម៌ខ្មែរគ្មានឈប់ឈរ ។ ថ្មី ៗ នេះនៅថ្ងៃទី ០៥ កញ្ញា ឆ្នាំ ២០០៤ អាជ្ញាធរយួន ឃុំចូវឡាំង ស្រុកស្វាយទង ខេត្តមាត់ជ្រូក បានលបលួចកាប់បំផ្លាញដើមគគីរដែលមានអាយុជាងមួយសតវត្សរ៍ នៅវត្តជីភ្លេង ឃុំចូវឡាំង អស់ ៤ ដើម ថែមទៀត ។*

វត្តជីភ្លេងក្រោម ស្ថិតនៅស្រុកស្វាយទង ខេត្តមាត់ជ្រូក កម្ពុជាក្រោម ។ វត្តជីភ្លេងក្រោម គឺជាវត្តមួយ ដែលយួនមានគោលបំណងយកដីវត្ត និងបំផ្លិចបំផ្លាញកុដិ សាលា ព្រះវិហារក្នុងទីអារាមនេះឲ្យវិនាសអន្តរាយកេរមត៌កជាតិខ្មែរ ។

កាលពីឆ្នាំ ១៩៧៨ យួនបានដេញព្រះសង្ឃ និងពុទ្ធបរិស័ទឲ្យចុះទៅរស់នៅខេត្តឃ្លាំង (HAU GIANG) ដោយសារសង្គ្រាមព្រំដែន ។ ឆ្លៀតក្នុងឱកាសនេះ យួនបានយកកុដិធ្វើកន្លែងដាក់ដី និងសាលាដាក់ថ្នាំជង្គូវ យកព្រះវិហារធ្វើជាជង្រុកស្រូវ និងកាប់បំផ្លាញដើមឈើទាំងឡាយ មានដើមគគីរ និងឈើទាលជាដើម ស្ទើរតែហិនហោចអស់ទៅហើយ ។

ពេលក្រោយមក ឆ្នាំ ១៩៨១ ទើបរដ្ឋការយួនសងវត្តមកឲ្យខ្មែរវិញ បច្ចុប្បន្ននេះ វត្តជីភ្លេងក្រោម ត្រូវរងគ្រោះយ៉ាងធ្ងន់ ដោយយួនយកដីជាច្រើនជាប់នឹងថ្នល់ជាតិដើម្បីសាងសង់សាលារៀន ។

ថ្មី ៗ នេះ គឺនៅថ្ងៃទី ០៥ កញ្ញា ឆ្នាំ ២០០៤ យួនបានរុះរើសាលារៀនមួយខ្នង មានពីរបន្ទប់ ដែលព្រះតេជគុណ ព្រះមេគណខេត្តមាត់ជ្រូក ព្រះនាម ជុំ សួន កសាងឡើងនៅឆ្នាំ ១៩៦៦ មានលក្ខណៈខ្មែរសម្រាប់កូនចៅរៀនសូត្រ ឥឡូវនេះយួនបានរុះរើយកកន្លែងសាងសង់សាលារៀនថ្មី ដើម្បីបំបាត់ភ័ស្តុតាងកេរដំណែលពីមុនមក ព្រមទាំងកាប់ដើមគគីរ ៤ ដើម ដើមត្នោត ២ ដើម នៅក្នុងបរិវេណដីវត្តនេះផងដែរ ៕ VOKK

# អាជ្ញាធរយួនដកសិទ្ធិព្រះចៅអធិការវត្ត ៤ អង្គនៅស្រុកជុំក្រុង ខេត្តព្រះត្រពាំង

*អាជ្ញាធរយួនខេត្តព្រះត្រពាំង ជាកន្លែងកើតព្រឹត្តិការណ៍ KC 50 បានបង្គាប់ឲ្យមន្ត្រីសង្ឃខ្មែរដកហូតងារជាព្រះចៅអធិការវត្ត ពីភិក្ខុសង្ឃ ៤ ព្រះអង្គនៅស្រុកជុំក្រុង ខេត្តព្រះត្រពាំង កាលពីចុងខែមីនា កន្លងទៅនេះ ។*

ព្រះភិក្ខុសង្ឃដែលរងគ្រោះដោយការដកហូតសិទ្ធិនោះគឺ ៖

១-ព្រះភិក្ខុ សឺន ង៉ុក កែវ ជាព្រះចៅអធិការវត្តកំពង់ក្សាយ

២-ព្រះភិក្ខុ ថាច់ ដើត ជាព្រះចៅអធិការវត្តស្តីទី វត្តកំពង់ក្សាយ ។

៣-ព្រះភិក្ខុ ថាច់ សុខ ជាព្រះចៅអធិការវត្តសំបូរឫទ្ធិស័ក្តិ ។

៤-ព្រះភិក្ខុ ត្រឹង យ៉ឹង ជាព្រះចៅអធិការវត្ត នាគវនារាម (ខ្ទឹង) ។

តាមសង្ឃដីការបស់ព្រះសង្ឃ និងពុទ្ធបរិស័ទចំណុះជើងវត្តទាំង ៣ ព្រមទាំងព្រះសង្ឃ និងពុទ្ធបរិស័ទចំណុះជើងវត្តដទៃទៀតនៅជិត ៗ វត្តដែលរងគ្រោះនោះ បានឲ្យដឹងថា "កាលពីរាត្រីថ្ងៃទី ២៦ មីនា មានករណីភិក្ខុសង្ឃ ១ អង្គនាម ថាច់ លីភោ គង់នៅវត្តកំពង់ក្សាយ ត្រូវបានអាជ្ញាធរយួនសហការជាមួយមន្ត្រីសង្ឃខេត្ត ចាប់ផ្សឹកនៅនឹងកន្លែង ហើយនាំខ្លួនយកទៅបាត់ ដោយមិនច្បាស់ពីមូលហេតុ ។

ប៉ុន្មានថ្ងៃក្រោយមក ស្រាប់តែគេឃើញមានសេចក្តីប្រកាសជាកោលាហលមួយ ចេញពីការិយាល័យមន្ត្រីសង្ឃខេត្ត ណែនាំដល់វត្តខ្មែរទាំង ១៤១ ទូទាំងខេត្ត មិនឲ្យទទួលស្គាល់ភិក្ខុទាំង ៤ ព្រះអង្គដែលមាននាមខាងលើក្នុងងារជាព្រះចៅអធិការវត្តតទៅទៀតទេ ។

ទាក់ទិននឹងការដកហូតសិទ្ធិជាព្រះចៅអធិការវត្ត នៃព្រះសង្ឃទាំង ៤ អង្គនេះ ព្រះមហាថេរព្រះនាម សឺន ង៉ុក កែវ ជាព្រះសង្ឃរងគ្រោះ បានមានថេរដីកាឲ្យដឹងថា ៖ "ព្រះអង្គមិនដឹងថាព្រះអង្គប្រព្រឹត្តអ្វីខុសទេ"។ ប៉ុន្តែបើតាមការកំណត់ទោសរបស់ព្រះអង្គដោយមន្ត្រីសង្ឃខេត្តថា ៖

ទី១-មានទោសដោយការអនុញ្ញាតឲ្យភិក្ខុថាច់ លីភោ ដែលជាជនប្រឆាំងរដ្ឋាភិបាលយួន ស្នាក់នៅក្នុងវត្តរបស់ព្រះអង្គ ។

ទី២-ព្រះអង្គមានទោស ព្រះអង្គមិនរាយការណ៍ដល់រដ្ឋអំណាចយួន នូវរាល់ទង្វើទាមទារសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯងរបស់ភិក្ខុ ថាច់ លីភោ នៅក្នុងវត្តរបស់ព្រះអង្គ ។

ទី៣-គឺព្រះអង្គគេចមិនផុតពីទោសរួមគំនិតនឹងភិក្ខុ ថាច់ លីភោ នោះឡើយ ។

ចំណែកព្រះមហាថេរ ត្រឹង យ៉ឹង ព្រះចៅអធិការវត្តនាគ-វនារាម (ខ្ទឹង) ព្រះអង្គមានថេរដីកាបំភ្លឺថា ៖ "មន្ត្រីសង្ឃបានកំណត់ទោសព្រះអង្គពីបទផ្សំគំនិតនឹងភិក្ខុ ថាច់ លីភោ ព្រោះថា តាំងពីមុនមកភិក្ខុ លីភោ ធ្លាប់និមន្តទៅមកទាក់ទងនឹងព្រះអង្គជានិច្ច" ។

ចំពោះបញ្ហាចោទប្រកាន់ ការបំបិទសិទ្ធិសេរីភាពរបស់មន្ត្រីសង្ឃខេត្តមកលើជាតិ និងព្រះសង្ឃខ្មែរ ខេត្តព្រះត្រពាំង ពុំទាន់មានប្រភពណាមួយអាចកំណត់បានថា បណ្តាលមកពីហេតុអ្វីឲ្យច្បាស់លាស់នោះបានឡើយ តែប្រភពភាគច្រើនបានបញ្ជាក់ថា "បញ្ហានេះវាបណ្តាលមកពីជាតិ និងព្រះសង្ឃខ្មែរទាំងនោះ ផ្សព្វផ្សាយនូវព្រឹត្តិ-បត្រ សៀវភៅ កាសែតចម្រៀង ព័ត៌មាន និង VCD ស្តីពីការបំពារ-បំពានរំលោភសិទ្ធិសេរីភាពពីសំណាក់របបអាណានិគមយួន មកលើជាតិមាតុភូមិខ្មែរកម្ពុជាក្រោម ៕ VOKK

# រឿងកំពប់តែអុង

អត្ថបទកំណាព្យនេះ ត្រូវបានរក្សាទុកអក្ខរាវិរុទ្ធតាមច្បាប់ដើមទាំងស្រុង

## សាស្ត្រាវត្តក្រូច - រៀបរៀងដោយសាស្ត្រាចារ្យ ឃឹន សុខ

(**តពីលេខមុន**)

៣៧៥-មួយសោតគាត់តែង សូត្រសែកសម្តែង
សិលសាស្ត្រគ្រប់កល សិងតែឆាប់ឆុត
ប្រាកដឥតទាល់ មនុស្សផងខ្សៀវខ្សា
មូលមកឥតរអ៊ក ។

៣៧៦-រស់រកភិក្ខុកែ នេនកុយបង្រៀរ
បង្ហូតឥតស្រាក គ្រុបថ្ងៃគ្រប់ខែ
ហូរហែឥតរអ៊ក ចេញចូលពឹងពាក់
រកសីលសាស្ត្រសៃយ ។

៣៧៧-ឮលេចខ្ចរខ្ចាយ ទៅស្រុកជិតឆ្ងាយ
គ្រប់ខែត្តទីទៃ សឹងចូលមូលមក
រកគាត់សព្វថ្ងៃ តាមតែប្រាស្រ័យ
រកអ្វីសិងបាន ។

៣៧៨-កាលនោះពុំស្ងាត់ ឮសេចខ្ចរខ្ចាត់
ដល់ក្សត្រប្រធាន ទាំងអុងបាហា
ដែលឈរនៅស្ថាន កំដរក្សត្រក្សាន្ត
សិងបានឮដាក់ ។

៣៧៩-ថាកើតសីលសង្ឃ អ្នកភិក្ខុមួយអង្គ
និងសម្មេម្នាក់ អស់រាស្ត្រទាំងឡាយ
ខ្វល់ខ្វាយពិងពាក់ ចេញចូលគ្រិកគ្រាក់
ឥតរអ៊កសព្វថ្ងៃ ។

៣៨០-មន្ត្រីយោធារ កែនធ្វើរាជការ
ពុំបានឡើយនៃ រាស្ត្រអាងសិលសង្ឃ
ប្រុងខ្លួនទីទៃ មេៗនោះនៃ
មិនហ៊ានខិតខំ ។

៣៨១-ស្តេចជ្រាបដូច្នេះ ទ្រង់គិតពិគ្រោះ
និងនាហ្មឺនធំ ទាំងអុងបាហោ
សិងមកជុំនំ ប្រើមន្ត្រីធំ
ទាំងពីរនោះហោង ។



យួនយកក្បាលខ្មែរធ្វើជាមុំចង្ក្រានកល់ដាំតែអុង

៣៨២-ប្រើទូនចៅហ្វារ សម្តេចចៅពញារ
នរេនតុលផង យកទាំងកៃព្រាល
ពលពាលកែនកង ច្រើនក្រៃកន្លង
ទ្រហឹងអឹងអ៊ប ។

៣៨៣-ទាំងពលយួនផង លើកទៅប៉ុនប៉ង
និងគិតចោមចាប់ ទៅដល់សីលកៃរ
ប្រែខ្មៃទាំងទ័ព ទាំងឡាយគិតកាប់
យួនអស់ឥតសល់ ។

៣៨៤-សម្តេចចៅពញា ទូនផរចៅហ្វា
និងរិះរកកល តទ័ពពុំបាន
បទគ្មានពួកពល ចូលគេឥតសល់
ទាំងកៃរព្រាលផង ។

៣៨៥-នរេនតុលក្តី ទោះទាំងមន្ត្រី
ខាងល្បួងនោះហង សឹងចូលសិលកៃរ
ខ្មៃព្រៃប្រឡូង កាប់យួនវិញហង
អស់ឥតគ្មានសល់ ។

៣៨៦-សម្តេចចៅពញា ទូនជរចៅហ្វារ

នឹងតាំងទ័ពទល់ នឹងគេពុំឈ្នះ
លាក់លាជ័យដល់ ហ្លួងនិងអុងយល់
ទូលជម្រាបទៅ ។
៣៨៧-តាមដោយរាជការ សព្វគ្រប់ប្រការ
ប្រាកដនោះកូវ ហ្លួងអុងបានជ្រាប
ដរាបស្មៀមនៅ យូរបន្តិចទៅ
បន្ទូលត្រាស់ថា ។
៣៨៨-ឲ្យហៅអស់ក្រុម ស្មៀនផងមកជុំ
ទើបមានឱងការ ឲ្យតែងបន្ទូល
រំពេជម្ទីម្នា ទើបមហាក្សត្រា
ឲ្យចេញជាឆាប់ ។
៣៨៩-ទើបអង្គអាមាត្យ ក្រាបលាព្រះបាទ
ទៅដោយបង្គាប់ ទាំងយប់ទាំងថ្ងៃ
រ៉ឹៗប្រញាប់ តាមទ្រង់បង្គាប់
ដល់ព្រៃនគរ ។
៣៩០-ដល់ហើយចរចូល នាំព្រះបន្ទូល
ក្សត្រក្សាន្តភូធរ ចូលដល់អុងធំ
ផ្គាញព្រៃនគរ ទើបអុងសួរមក៍
មានបើហេតុអ្វី ។
៣៩១-ទើបឯអាមាត្យ ហុចបន្ទូលស្អាត
ទៅអុងនោះខ្ចី អុងឲ្យថីឡាយ
សូត្រស្រាយសេចក្តី សព្វគ្រប់អំពី
កង្វល់ស្រុកខ្មែរ ។
៣៩២-បទមានសិលសង្ឃ អភិកម្មួយអង្គ
នាមនោះឈ្មោះកែ អុងតាគុនតឹង
ដំណឹងស្រុកខ្មែរ ដូច្នោះប្រុងប្រែ
ប្រដាប់ជើងទឹក ។
៣៩៣-ទ័ពទូកចម្បាំង ពលពាលស្រីតស្រាំង
ច្រើនក្រៃសន្ធឹក ទង់ជ័យដេរដាស
ពេញពាសសន្ធឹក គ្រប់គ្រឿងជើងសឹក
ស្រេចហើយចរចេញ ។
៣៩៤-អស់អុងបម្រើ ដែលតាគុនប្រើ
មកចម្បាំងនោះមិញ ខឹងនឹងសិលកែ
បទតែគាត់ចេញ កាប់យួននោះមិញ
មិនចូលស្តេចឡើយ ។
៣៩៥-លើកលែងបាភ្នំ សន្ធរត្បូងឃ្មុំ
ព្រៃវែងនោះហើយ តាំងទ័ពគោគទឹក
ពន្លឹកជាត្រើយ តទល់គ្នាហើយ
ឥតបានបង្អង់ ។
៣៩៦-កាលនោះតាកែ បង្កប់ពលខ្មែរ
សូត្រសែកសិលសង្ឃ ឲ្យមានតេជា
រឹតត្បាពលពង្ស រលាស់ទឹកត្រង់
ពលពាលទាំងឡាយ ។
៣៩៧-ឲ្យឈ្នះសត្រូវ កុំឲ្យយួនទៅ
បាក់បែកខ្ចាត់ខ្ចាយ បើយួននោះចាញ់
ឲ្យចេញជាឆ្ងាយ កុំឲ្យមករអាយ
ដល់ពលខ្មែរឡើយ ។
៣៩៨-បង្កក់រួចស្រេច តាំងទ័ពរំពេច
ពិតពុំព្រងើយ លើកចេញដេញយួន
យួនបាញ់មកហើយ ពុំត្រូវខ្មែរឡើយ
ស្បើយធ្លាក់មិនដល់ ។
៣៩៩-រីឯកែព្រាល ស្ទុះទៅកណ្តាល
និងនរេនតុល គាត់មានកំឡាំង
ខ្លាំងលើសអស់ពល គាត់ស្ទុះទៅដល់
ពលយួនទាំងឡាយ ។
៤០០-ភិតភ័យភ័នភាំង តក់ស្លុតស្លាំងកាំង
ទន់អស់អង្គារ កែព្រាលគាត់កាប់
បាក់ទ័ពខ្ចាត់ខ្ចាយ ពលយួនទាំងឡាយ
លុះក្បៀយជន្មា ។
៤០១-រង្គាវង្គាល ខ្ចាយឈាមច្រាសច្រាល
ពាសពេញសុធារ ដូចគេកាប់ចិត
ដួសដេកត្រៀបត្រា យួនយល់រអារ
បាក់បែកទ័ពទៅ ។
៤០២-ទោះទាំងជើងទឹក ពលយួនភ្លាំងភ្លឹក
ពុំអាចនិងនៅ ខ្លាចទ័ពតាកែរ
ពលខ្មែរដេញទៅ ពុំអាចនិងនៅ
ថយទៅភ្នំពេញ ។
៤០៣-ឯអស់ពលយួន ដែលដួលស្លាប់ខ្លួន
ទាំងអស់នោះមិញ ចោលទាំងគ្រឿងក្រោះ

(**នៅមានត**)

កំណាព្យ

# សម្រែកខ្មែរក្រោម ក្រោមនឹមដែកអំរែកភ្នំយួន

ឱជាតិខ្មែរអើយទាំងលើក្រោម សាសន៍យួនចោមរោមតាមប្រល័យ
តាមសម្លាប់ខ្មែរតែរាល់ថ្ងៃ ពុំដែលសំចៃរាល់វេលា ។
ជាតិជាខេមរាផ្សាក្នុងចិត្ត ទុក្ខសោករួមរិតចិត្តគ្រាំគ្រា
ហៀមក្រូសហៀមគ្រប់គ្រប់វេលា ជូរចត់គ្រាំគ្រាក្រៃកន្លង ។
ទឹកភ្នែកខ្មែរក្រោមហូរសស្រាក់ មានអ្នកធ្វើខ្វាក់ធ្វើគថ្លង់
អម្បូរខ្មែរស្លាប់មិនស្រោចស្រង់ ស្លាប់អសារបង់ឥតអាកាស ។
ទឹកភ្នែកខ្មែរក្រោមហូរជាស្ទឹង សញ្ជាប់សញ្ជឹងពឹងឱកាស
ខ្មែរក្រោមខ្លាចស្លាប់តោងគេចចៀស ជម្លៀសភៀសខ្លួនផុតភិតភ័យ ។
ខ្មែរក្រោមប្រុសស្រីរាប់លាននាក់ ជឿជាក់លើប្រជាធិបតេយ្យ
ដែលពេញនិយមក្នុងលោកកិយ ប្រជាសេរីដ៏ឧត្តម ។
ឱជាតិខ្មែរអើយយើងសាមគ្គី កម្លាំងមូលមីឲ្យមួនមាំ
យើងត្រូវរួបរួមខំអប់រំ ព្យាយាមសន្សំភាពភក្តី ។
ពេលកន្លងហួសកុំទោម្នេញ គិតគូរឡើងវិញរឿងទឹកដី
ដែលបានបាត់បង់នៅថ្មីៗ គឺដែនដីនៅកម្ពុជា ។
VINCENT AURIOL ចូលប្លន់ដី ប្លន់ខ្មែរប្រុស ស្រី អុំ មីង មា
ប្លន់ទឹកប្លន់ដីកម្ពុជា យកសិទ្ធិមីងមាចូលនឹមយួន ។
PAUL COSTE PLORET រដ្ឋមន្ត្រី លូកដៃយកដីមិនត្រូវក្បួន
យកទឹកដីខ្មែរទៅឲ្យយួន ធ្វើនោះសមសួនឬយ៉ាងណា ។
មួយពាន់ប្រាំបួនរយសែសិបប្រាំបួន (១៩៤៩) ចុះថ្ងៃទី បួន (៤) មិថុនា
បារាំងធ្វើសិន្ធិសញ្ញា ប្លន់ដីខេមរាឲ្យបៅដាយ ។
ភាពល្វីងជូរចត់បានចុកចាប់ ឃើញច្បាប់បារាំងនឹកសោកស្តាយ
ចិត្តខ្មែរស្នេហាជាតិទាំងឡាយ នាំគ្នាខ្វល់ខ្វាយស្តាយទឹកដី ។
ស្តាយណាស់ស្តាយណាស់ទាំងគេខ្ញុំ ពួកខ្មែរស្រែកយំទាំងប្រុសស្រី
ស្រែកយំទាមទារសិទ្ធិសេរី ព្រោះខ្មែរម្ចាស់ដីជាប់នឹមយួន
ឱជាតិខ្មែរអើយសូមកុំខ្លាច បង្កើតអំណាចតាមច្បាប់ក្បួន
យើងទាមទារដីពីដៃយួន យើងធ្វើតាមក្បួនកុំកោតក្រែង
ក្បែលយើងយើងដុះទើបបានជ្រះ កុំដេកបន់ព្រះឲ្យជ្រះឯង
ស្លូតស្លាប់ឥតការណាក្រែង បើយើងប្រឹងប្រែងនរណាហ៊ាន ៕

**សោម ផល**




**បញ្ញាសជាតក**
**រឿងទី ១៧**

*ជាស្នាដៃនិពន្ធរបស់លោក ញ៉ុក ថែម*
*បោះពុម្ពលើកទី ១ នៅភ្នំពេញ ឆ្នាំ ១៩៥៩*

# រឿងវិរិយបណ្ឌិត

មានសេចក្តីដំណាលថា ព្រះរាជាដែនបញ្ចាលរដ្ឋ បានចាត់រាជបម្រើឲ្យនាំសំពត់រត្នកម្ពលមានថ្លៃច្រើន ទៅថ្វាយព្រះបាទមហារដ្ឋរាជ ។ ទ្រង់បានទតឃើញសំពត់នោះហើយ ទ្រង់ព្រះបិន្តាថា មហាមិត្តអញបានផ្ញើរបស់មានតម្លៃមកឲ្យអញ គួរអញរករតនវត្ថុដែលមានតម្លៃជាង ផ្ញើតបទៅវិញទើបគួរ ទ្រង់យល់ថា រតនវត្ថុមានតម្លៃ គ្មានអ្វីស្មើនឹងព្រះពុទ្ធរតនៈឡើយ ដូច្នេះគួរអញសាងព្រះពុទ្ធបដិមា ផ្ញើទៅថ្វាយសម្លាញ់អញវិញ ហើយទ្រង់បញ្ជាឲ្យជាងមាសផែមាសសាងជាព្រះពុទ្ធបដិមា ទើបព្រះរាជាចាត់រាជទូត ឲ្យនាំព្រះពុទ្ធបដិមាទៅថ្វាយព្រះបាទបញ្ចាលរាជ ដោយក្បួនដង្ហែតាមនាវា ។ ព្រះរាជាទ្រង់ថ្វាយបង្គំព្រះពុទ្ធបដិមា ទ្រង់ត្រាស់ថា “បពិត្រព្រះអង្គដ៏ចម្រើនព្រះបាទបញ្ចាលរាជជាសំឡាញ់របស់ខ្ញុំព្រះអង្គ ជាមនុស្សមិច្ឆាទិដ្ឋិ សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសសង្គ្រោះស្តេចនោះ ឲ្យបានឋិតនៅក្នុងផ្លូវសម្មាទិដ្ឋិ បើព្រះអង្គទៅដល់នគរបញ្ចាលហើយ សូមទ្រង់ធ្វើបាដិហារ្យបង្កើតក្តីជ្រះថ្លាដល់ស្តេចនោះ ដោយក្តីមេត្តាសង្គ្រោះប្រោសប្រណីនៃព្រះអង្គ” ។ ព្រះបាទមហារដ្ឋរាជ ទ្រង់បានបួងសួងយ៉ាងនេះ ទ្រង់យាងចុះដូនដំណើរព្រះពុទ្ធបិមា ត្រាតែដល់ជម្រៅទឹកត្រឹមព្រះស្សូរង ។ ខណៈនោះ ផ្ទៃសមុទ្រមានផ្ការទឹករាបសាល្អ មានបទុមជាតិ បញ្ចពណ៌ធំផុសលេចឡើងលើផ្ទៃទឹក ធ្វើសក្ការបូជាព្រះពុទ្ធបដិមា ។ ពួកនាគរាជក៏នាំគ្នាបូជាដោយគន្ធមាលាផ្សេង ៗ ហើយហក់ហែលចោមរោមជាបរិវារ ។ ពួកអាកាសទេវតា ក៏រោយរាយបាចសាចទិព្វបុប្ផាផ្សេង ៗ អំពីអាកាស ប្រគំតូរ្យតន្ត្រី ឮសូររងំពិរោះល្វេងល្វើយ គួរជាទីអស្ចារ្យណាស់ ។

រាជទូតទាំងឡាយ បានបើកភេត្រាដ៏មានសិរីដរាបដល់ទៅនគរបញ្ចាល នាំគ្នាចូលគាល់ ក្រាបទូលដំណាលពីហេតុអស្ចារ្យផ្សេង ៗ ។ ព្រះរាជាទ្រង់មានព្រះទ័យសោមនស្សក្រៃលែង ទ្រង់បានចាត់ចែងគ្រឿងសក្ការបូជាជាអនេកប្រការ ស្តេចព្រមដោយអាមាត្យមន្ត្រីចោមរោមជាបរិវារនឹងមហាជន ទៅទទួលព្រះពុទ្ធបដិមាអំពីភេត្រា ទ្រង់បានក្រាបថ្វាយបង្គំ ទ្រង់បានបូជាដោយទៀនធូបគន្ធមាលា ដោយសេចក្តីគោរព ទ្រង់ត្រាស់ថា “បពិត្រព្រះដ៏មានបុណ្យអើយ ទូលព្រះបង្គំសូមព្រះអង្គជាទីពឹងទីរឭកដរាបដល់អស់ជីវិត សូមព្រះអង្គទ្រង់ជ្រាបថាទូលបង្គំជាឧបាសកគោរពព្រះរតនត្រ័យ តាំងពីថ្ងៃនេះជាដើមទៅ” ។

ព្រះពុទ្ធបដិមា ទ្រង់បានសម្តែងបាដិហារ្យយ៉ាងអស្ចារ្យអណ្តែតឡើងលើអាកាស បានបញ្ចេញឆព្វណ្ណរង្សីរស្មីទាំងប្រាំមួយពណ៌ គឺ ខៀវ លឿង ក្រហម ស ហង្សបាទ នឹងពណ៌ចម្រុះផ្សាយចេញឆ្លៀលធ្លាត់ភ្លឺព្រោងព្រាយពណ្ណរាយ ផ្សព្វផ្សាយចេញទៅសព្វទិសទាំងពួង ។ ពួកទេពតានាំគ្នាធ្វើសក្ការៈបូជាឋិតឰដ៏អាកាស ។ ពួកមនុស្សម្នាមហាជន ចេញពីទីតំបន់ផ្សេង ៗ នាំគ្នាធ្វើសក្ការៈបូជានាផែនដី ។ គ្រានោះពួកមនុស្ស និងពួកទេវតា បានមើលឃើញគ្នាទៅវិញទៅមកដោយជាក់ច្បាស់ ។

ព្រះរាជាបានក្រាបទូលនិមន្តសូមព្រះពុទ្ធបដិមា យាងចុះមកលើសុពណ៌សិវិកា ដែលទ្រង់បានចាត់ចែងបម្រុងទុក ។ លុះព្រះពុទ្ធបដិមាយាងចុះមកហើយ ទ្រង់ព្រមដោយចតុរង្គ-សេនា អាមាត្យមុខមន្ត្រីនឹងមហាជន បានដង្ហែចូលព្រះនគរ ។ ទ្រង់បានឲ្យជាងធ្លាក់ព្រះពុទ្ធរូបមួយអង្គទៀត ធ្វើពីខ្លឹមច័ន្ទន៍ ហើយទ្រង់ឲ្យដំកល់ទុកក្នុងសាលា ទ្រង់ឲ្យប្រកាសផ្សាយដំណឹងថា ជនណាមួយមានមាសតិចក្តី ច្រើនក្តី ចូរយកមកទីបព្រះពុទ្ធបដិមាជាមួយនឹងយើងតាមសទ្ធាជ្រះថ្លារៀងខ្លួនចុះ” ។

កាលណោះ មានបុរសកំសត់ម្នាក់ ឈ្មោះវិរិយបណ្ឌិត ជាអ្នកមានសទ្ធាជ្រះថ្លាខ្លាំង មានបំណងនឹងលក់ខ្លួនទិញមាស

ទឹបព្រះពុទ្ធរូបនោះ តែប្រពន្ធកូនពុំយល់ព្រមឲ្យស្វាមី និងបិតាធ្វើដូច្នោះទេ គឺអ្នកទាំងពីរសុខចិត្តលក់ខ្លួនប្រាណជំនួស បានប្រាក់ប្រែគល់ជូនស្វាមីខ្លួន ឲ្យយកទៅទិញមាសទឹបព្រះពុទ្ធបដិមា ។ អ្នកបានមាសហើយ ចូលទៅក្នុងសាលាប្រាថ្នានឹងទឹបព្រះពុទ្ធរូប តែអ្នកយាមរក្សាពុំយល់ព្រម ដោយអាងថា ព្រះរាជាពុំទាន់យាងមកទឹបទេ អ្នកដទៃទឹបពុំបានឡើយ ដ្បិតខុសនឹងទំនៀមទម្លាប់ ។ វីរិយបណ្ឌិតនិយាយអង្វរខ្លាំងពេក អ្នកយាមរក្សាក៏ប្រាប់ថា ឲ្យអ្នកឯងចូលទៅក្រាបទូលសូមព្រះរាជាអនុញ្ញាតសិន ។ អ្នកបានសុំចូលគាល់ក្រាបទូលតាមដំណើរ ។ ព្រះរាជាត្រាស់ថា “បើព្រះពុទ្ធបដិមា មានព្រះពុទ្ធដីកាអនុញ្ញាតឲ្យអ្នកឯង ៗ ទឹបមុនយើងចុះ” ។

វីរិយបណ្ឌិត ក៏ក្រាបថ្វាយបង្គំលាព្រះរាជា រលះរលាំងត្រឡប់មកកាន់សាលាវិញ ហើយអ្នកតាំងចិត្តអធិដ្ឋានដោយពោលអាងនូវពាក្យសច្ចៈផ្សេង ៗ ដើម្បីសូមឲ្យព្រះពុទ្ធបដិមាបើកព្រះឱស្ឋមានព្រះពុទ្ធដីកាឲ្យបានឃើញជាក់ស្ដែងប្រាកដ ។

គ្រានោះ ទេវតារក្សាព្រះនគរបានចូលជ្រែកក្នុងអង្គព្រះបដិមា ធ្វើឲ្យព្រះបដិមាខ្លឹមច័ន្ទន៍មានជីវិតរស់រវើកឡើងយ៉ាងអស្ចារ្យបញ្ចេញព្រះពុទ្ធដីកាថា “វីរិយបណ្ឌិត ចូរអ្នកទឹបតថាគតតាមប្រាថ្នាចុះ” ហើយបានបញ្ចេញរស្មីទាំងប្រាំមួយពណ៌ ដូចព្រះពុទ្ធបដិមាអង្គមុននោះដែរ ។ វីរិយបណ្ឌិត ក៏បានទឹបព្រះពុទ្ធបដិមាដោយមាសដែលខ្លួនមានទាំងប៉ុន្មាននោះ ។ ព្រះរាជាទ្រង់បានជ្រាបព័ត៌មាននោះ ក៏ឲ្យហៅវីរិយបណ្ឌិតមក ហើយទ្រង់បានព្រះរាជទានសម្បត្តិផ្សេង ៗ ច្រើនអនេក ។ អ្នកនគរក៏បាននាំមាសប្រាក់សំពត់ជាដើមមកជូនអ្នកយ៉ាងកកកុញ ។ អ្នកបានរស់នៅរួបរួមជាមួយនឹងគ្រួសារជាសុខក្សេមក្សាន្ត ដរាបដល់ក្ស័យជីវិត ៕



*គណៈប្រតិភូព្រះសង្ឃខ្មែរកម្ពុជាក្រោម ចូលរួមប្រជុំក្នុងវេទិកាអចិន្ត្រៃយ៍អង្គការសហប្រជាជាតិស្ដីអំពីបញ្ហាជនជាតិដើម ចាប់ពីថ្ងៃទី ១៦ ដល់ ២៧ ខែឧសភា ឆ្នាំ ២០០៥ នៅបូរីញូវយ៉ក សហរដ្ឋអាមេរិក ។*